ព្រះសង្ឃរាជមួយព្រះអង្គរបស់ប្រជាជន

សម្តេចព្រះញ៉ាណាសំវរ

ព្រះសង្ឃរាជជាន់ខ្ពស់របស់ប្រទេសថៃ

ព្រះសង្ឃរបស់ប្រជាជន

សម្តេចព្រះញ្ញាណសំវរ
ព្រះសង្ឃរាជនៃប្រទេសថៃ

"ការប្រាថ្នាឲ្យអ្នកដទៃបានទទួលសេចក្តីសុខ
គឺជាអ្វីដែលមនុស្សគ្រប់រូបគប្បីធ្វើ
ពីព្រោះការប្រាថ្នាបែបនេះគឺជាគុណភាពផ្លូវចិត្តដ៏សំខាន់ ដែលហៅថា
"មេត្តា" ។ មេត្តា តាមន័យត្រង់ មានសេចក្តីថា "ការស្រឡាញ់
"។ ប្រសិនបើចិត្តរបស់បុគ្គលណាមួយពោរពេញដោយមេត្តា
បុគ្គលនោះពិតជាមានសេចក្តីសុខ មិនខាន"។

Sd. Phra Nyanasamvara

ព្រះសង្ឃរបស់ប្រជាជន

សម្តេចព្រះញាណសំវរ ព្រះសង្ឃរាជនៃប្រទេសថៃ

Published by Department of Religious Affairs
Copyright @2015
First Published July 2015: 2,000 Copies
ព្រះធម្មឃោសាចារ្យ បណ្ឌិត ឃី សុវណ្ណរតនា ព្រះសីហនុរាជ, កម្ពុជា

Advisors:

1.	His Eminence Somdet Phra Wanarat (Chund Brahmagutto)	
2.	Venerable Phra Shakyavongsvisuddhi (Dr. Anil Man Dhammasakiyo)	
3.	Mr.Kitsayapong Siri	Director-General, Department of Religious Affairs
4.	Mr.Sutep Kasempornmanee	Deputy Director-General, Department of Religious Affairs
5.	Mr. Pisit Nirattiwongsakorn	Director of Religious Patronage Division
6.	Mrs. Pilai Jirakaisiri	Director of Moral and Ethical Encouragement Bureau

Publication Committee:

1.	Mr.Kriansak Boonprasit	Chairperson	Secretariate to the Religious Department
2.	Assoc. Prof. Dr. Sophana Srichampa	Director, Research Institute for Languages and Cultures of Asia, Mahidol University	member
3.	Mr.Poolsak Sukhsaptaweephol		member and Secretary
4.	Mr. Suriya Wiwatkitlert		member and Deputy-Secretary
5.	Mr. Narut Dhammadhi		member and Deputy-Secretary

Printed by THE AGRICULTURAL CO-OPERATIVE FEDERATION OF THAILAND., LTD.
79 Ngamwongwan Rd., Ladyao Chatuchak Bangkok 10900 THAILAND.
Tel. 0-2561-4567, 0-2561-4590-6
Fax. 0-2579-5101, 0-2941-1230

អារម្ភកថា

សម្តេចព្រះញាណសំវរ (ច្រើន សុវឌ្ឍនោ) អតីតសម្តេចព្រះសង្ឃរាជជំនាន់ទី១៩ យុគរតនកូសិននៃប្រទេសថៃ គឺជាភិក្ខុមួយអង្គដែលមានការប្រព្រឹតដ៏ប្រសើរៗព្រះអង្គបានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនតាមកិច្ចវត្តអ្នកបួសពុទ្ធសាសនាដែលស្តែងចេញនូវឥរិយាបថរបស់អ្នកបួសដ៏ប្រពៃ។ ព្រះអង្គមានការប្រព្រឹត្តឥតខ្ចោះ ប្រកបដោយគុណធម៌និងមេត្តាធម៌ ដែលជាគុណសម្បត្តិធ្វើឲ្យពុទ្ធបរិស័ទស្រឡាញ់ព្រះអង្គគ្រប់ៗគ្នា។ ព្រះអង្គជាសម្តេចព្រះសង្ឃរាជនៃប្រទេសថៃ។ ព្រះអង្គសុភាពរាបសារ ប៉ុន្តែប្រតិបត្តិព្រះធម៌វិន័យយ៉ាងតឹងរឹង។ ព្រះអង្គបានផ្សព្វផ្សាយព្រះពុទ្ធសាសនានិងពុទ្ធវចន:នៅគ្រប់ទិសទីទាំងអស់ក្នុងពិភពលោក ទាំងអាស៊ី ទាំងអឺរ៉ុប និងតំបន់ដទៃៗទៀត រហូតដល់ព្រះអង្គសោយទីវង្គត។

បេសកកម្មមួយនៃបេសកកម្មទាំងឡាយរបស់នាយកដ្ឋានកិច្ចការសាសនា នៃ ក្រសួងវប្បធម៌ គឺលើកស្ទួយនិងទ្រទ្រង់សកម្មភាពសាសនាទាំងឡាយ ជាពិសេស ព្រះពុទ្ធសាសនា។ នៅចុងឆ្នាំ ២០១៥ ប្រទេសថៃនឹងធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍អាស៊ាន។ ដើម្បីអបអរសាទរ នាយកដ្ឋានកិច្ចការសាសនារៀបចំបោះពុម្ពសៀវ ភៅនេះ ដែលមានចំណងជើងថា “ព្រះសង្ឃរបស់ប្រជាជន: សម្តេចព្រះញាណសំវរ ព្រះសង្ឃរាជនៃប្រទេសថៃ”។ សៀវភៅនេះ គឺជាការប្រមូលចងក្រងនូវព្រះជីវប្រវត្តិសម្តេចព្រះញាណសំវរ និង ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលសម្តេចបានលើកយកមកបង្រៀននៅក្នុងសៀវភៅនានា និងនៅក្នុងឱកាសផ្សេងៗ។ ការបោះពុម្ពនេះនឹងមិនគ្រាន់តែមានប្រយោជន៍ដល់អ្នកអានប៉ុណ្ណោះទេ ប៉ុន្តែ វាជាមហាកុញ្ជាតធម៌មួយក្នុងការផ្សព្វផ្សាយនូវព្រះកិត្តិនាមរបស់សម្តេចព្រះញាណសំវរ ព្រះសង្ឃរាជនៃប្រទេសថៃ ឲ្យកាន់តែទូលំទូលាយ។ ក្នុងន័យនេះ នាយកដ្ឋានកិច្ចការសាសនារៀបចំបោះពុម្ពសៀវ ភៅជីវប្រវត្តិដែលមានចំណងជើងថា “ព្រះសង្ឃរបស់ប្រជាជន: សម្តេចព្រះញាណសំវរ ព្រះសង្ឃរាជរបស់ប្រទេសថៃ” ជាប្រាំបីភាសាផ្សេងគ្នា គឺ: ថៃ អង់គ្លេស ភូមា ខ្មែរ លាវ ឥណ្ឌូនេស៊ី វៀតណាម និងនេប៉ាល់។

នាយកដ្ឋានកិច្ចការសាសនា សូមថ្លែងអំណរព្រះគុណ សម្តេចព្រះវនរ័ត្ន (ចុន្ទ ព្រហ្មគុត្តោ) និងព្រះតេជគុណព្រះសាក្យវង្សវិសុទ្ធិ (បណ្ឌិត អានិល ម៉ាន់ ធម្មសាកិយោ) គង់នៅវត្តបវរនិវេសវិហារ ដែលព្រះអង្គទាំងទ្វេមានព្រះទ័យករុណាទទួលធ្វើជាទីប្រឹក្សានៃការបោះពុម្ពនេះ និងបានពិនិត្យនូវសំណៅដើមទាំងប្រាំបីភាសាយ៉ាងហ្មត់ចត់។ ខ្ញុំសង្ឃឹមយ៉ាងស្មោះថា សៀវភៅទាំងប្រាំបីភាសាផ្សេងគ្នានិងផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់សាធារណៈជនទូទៅ។

ក្រិតយាវង្ស សិរី

អគ្គនាយក, នាយកដ្ឋានកិច្ចការសាសនា

មាតិការ

ទំព័រ

៥	តាពសំបូរបុងរឿងឥតខ្ចោះ
៨	ជីវិតថៃអាំដោយព្រះធម៌
១២	ព្រះសង្ឃដែលស្រលាញ់ការអប់រំ
១៧	ការស្វែងរកព្រះធម៌
២១	ភ្លិនផ្កែមថ្យូថ្យាយពេញពិភពលោក
២៥	សសរស្តម្ភនៃព្រះពុទ្ធសាសនា
៣០	ជោតិភាពរបស់ព្រះអង្គ
៣៨	ជីវិតព្រហ្មចរិយៈរបស់សម្តេច
៤៤	តិក្ខុប្រកបដោយករុណា
៤៨	ព្រះអគ្គសង្ឃរាជ

ភាពសំបូរបែរជីវតខ្វះ

"អាជិត ដ៏រាបណារលកតណ្ហានៅមាន ចូរប្រើប្រាស់សតិដើម្បីទប់ស្កាត់។ ដូច្នេះ សតិការពាររារាំងនូវរលកទាំងនោះ។
បញ្ញាដើម្បីទប់នូវរលកតណ្ហាទាំងឡាយឲ្យនៅនឹងថ្កល់បានឈ្មោះថា "ញាណសំវរ"។
(អត្តកថាមូលបរិយាយសូត្រ, ម.និ. ១)

ជាងមួយសតវត្សកន្លងទៅហើយនៅបានលឺ ភូមិដ៏តូចមួយតាំងនៅមាត់ច្រាំងនៃ ទន្លេខ្វែដ៏ស្រស់ស្អាតមួយ ក្នុងស្រុកម្យឹង ខេត្តកញ្ចនបូរី នៅថ្ងៃ៥កើត ខែកក្តិក ឆ្នាំឆ្លូវ ត្រូវនឹងថ្ងៃទី៣ ខែតុលា ឆ្នាំ១៩១៣ ទារកមួយបានប្រសូត្រនូវក្នុងត្រកូលគជវត្រ។

នៅពេលនោះ គ្មាននរណាម្នាក់ដឹងនូវឡើយថាកុមារតូចម្នាក់នេះនឹងមានវាសនា អស្ចារ្យក្លាយទៅជាព្រះសង្ឃរាជទី១ ៩ នៃព្រះរាជាណាចក្រថៃ។ សម្តេចព្រះញាណសំវរព្រះសង្ឃរាជ ត្រូវបានគេប្រសិទ្ធនាមថា "ច្រើន"។ ព្រះអង្គជាកូនច្បងរបស់លោក ណយ គជវត្រ ជាអភិបាលរង ស្រុកអាំប្រាវា ខេត្តសមុទ្រសង្គ្រាម។ ខ្សែស្រឡាយ ណយ មានតំណតាំងពីសម័យអយុធ្យានិងជាប់ទាក់ទិនជាមួយគ្រួសារអភិជន "ណ: តគោតថុង" នៅភូមិភាគខាងត្បូងប្រទេសថៃ។ គីម ណយ ជាមាតាកុមារនេះ ធ្វើការជាជាងកាត់ដេរ ចេញពីត្រកូលវង្សសាវាង ដែលមានដូនតាជាចិនផងដែរ។

សម្តេចព្រះសង្ឃរាជបានប្រសូត្រនៅគេហដ្ឋានវង្សសាវាន ស្ថិតនៅផ្លូវប៉ាក់ប្រេកនៅផ្ទះដដែលហ្នឹង ប្អូនប្រុសពីរនាក់គឺ: ចាំងៀង និង សមុទ្រ និងបងប្អូនជាដូនមួយរបស់ព្រះអង្គបានប្រសូត្រ។ ក្នុងវ័យកុមារភាព ព្រះអង្គបានទទួលនូវសេចក្តីស្រឡាញ់និងមេត្តាធម៌យ៉ាងច្រើនព្រមទាំងត្រូវបានបីបាច់ថែរក្សាដោយសមាជិកគ្រួសារនិងញាតិទាំងឡាយដែលរស់នៅភូមិផងរបងជាមួយ។

ទោះបីសម្តេចមានភ័ព្វវាសនាទទួលបាននូវការចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយ បរិយាកាសជាទីស្រលាញ់នឹងធឹងក៏ដោយ ក៏ព្រះអង្គមានសុខភាពមិនល្អជារហូតក្នុងវ័យកុមារភាព។ នៅពេលមួយនោះ ពេលព្រះអង្គកំពុងមានជំងឺធ្ងន់ សមាជិកគ្រួសារម៉ៅមច្បងបានបួងសួងឲ្យព្រះអង្គបានជាស្បែ

ស្បើយដោយសច្ចាថា ព្រះអង្គនឹងបួសជាសាមណេរក្រោយពេលជាស្បះស្បើយពីជំងឺ។

បន្ទាប់ពីបិតារបស់ព្រះអង្គទទួលអនិច្ចកម្មទៅ ខណៈពេលសម្តេចមានអាយុទើបតែ៩ឆ្នាំ គ្រួសាររបស់ព្រះអង្គបានជួបនឹងបញ្ហាស្មុគស្មាញរឿងលុយកាក។ ព្រះអង្គក៏ត្រូវបានគេបញ្ជូនទៅរស់នៅជាមួយម្តាយធំឈ្មោះ គីមហេង ជាបងស្រីបង្កើតរបស់មាតាព្រះអង្គ។

ទោះបីជាព្រះអង្គមានការនឹករលឹកដល់ក្រុមគ្រួសាររបស់ព្រះអង្គ ទឹកចិត្តដ៏កក់ក្តៅនិងការថ្នាក់ថ្នមដ៏ទន់ភ្លន់ទីស្រឡាញ់របស់ម្តាយធំ គីមហេង បានធ្វើឲ្យជីវិតកុមារតូចនេះទទួលបាននូវភាពរីករាយនឹងភាពកក់ក្តៅ។ ព្រះអង្គបានក្លាយទៅជាកុមារជាទីស្រឡាញ់ចំពោះអ៊ុំស្រី ហើយតែងតែស្ថិតនៅក៏កិតជាមួយនឹងម្តាយធំ។

គេហដ្ឋានក្រុមគ្រួសារវង្សសាវាងមានទីតាំងជិតវត្តបីគឺ: វត្តទេវសង្ឃារាម (វត្តនឿ-វត្តខាងជើង) វត្តជ័យភូមិផលឈ្នះសង្គ្រាម (វត្តតែ-វត្តខាងត្បូង) និងវត្តថាវរ (វត្តឃួន-វត្តកាន់ចឹតតឹន)។ ក្នុងនាមជាពុទ្ធសាសនិកដ៏មុតមាំម្តាយធំ គីមហេង និងមាតាកុមារតូចនេះ ជារឿយៗតែងតែទៅចូលរួមពិធីបុណ្យទានទៅឯវត្តជិតខាងហើយតែងតែនាំសម្តេចទៅជាមួយដើម្បីបន្សាំព្រះអង្គទាំងនៅវ័យក្មេងទៅនឹងជំនឿសាសនា ដែលព្រះអង្គបានទទួលយក។ ក្នុងកំឡុងរដូវចូលព្រះវស្សារយៈពេលបីខែ ដែលព្រះសង្ឃថេរវាទតែងតែបដិបត្តិជារៀងរាល់ឆ្នាំ កុមារតូចនេះតែងអង្គុយស្តាប់ធម៌រៀងរាល់ល្ងាចនៅវត្តនឿ។ ទង្វើនេះបង្ហាញថា សម្តេចបានយល់ដឹងអំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធតាំងពីវ័យកុមារម្ល៉េះ។

ក្នុងនាមជាកុមារពីសនឹងមានភាពរហ័សរហួន សម្តេចបានរំលឹកឃើញនូវអ្វីដែលសម្តេចបានសង្កេតនៅឯវត្តនិងបានប្រើការស្រមើស្រមៃរបស់ព្រះអង្គលេងល្បែងកុមារដែលតំណាងឲ្យពិធីបុណ្យសាសនាដែលព្រះអង្គបានចូលរួម។ ព្រះអង្គចូលចិត្តលេងធ្វើជាអ្នកបួស សម្តែងធម៌ទេសនា កាន់ស្លឹកត្នោតដងវែងជំនួសឲ្យធ្នឹតតាលីបុត ដែលជាធ្នឹតព្រះសង្ឃថៃតែងកាន់ ដូចដែលព្រះអង្គតែងសង្កេតឃើញនៅឯវត្ត។

ល្បែងមួយទៀតដែលមានឈ្មោះថា “ចោលកញ្ជើរ” ជាពិធីប្រចាំឆ្នាំ ដែលគេជូនម្ហូរអាហារនិងបរិក្ខារផ្សេងៗដល់ជនក្រីក្រ។ បុណ្យកុសលដែលកើតចេញពីកុសលកម្មទាំងនោះ គេឧទ្ទិសដល់ប្រេតដែលកំពុងរងទុក្ខនិងអត់ឃ្លានអាហារ។ ព្រះអង្គបានស្នើឲ្យកុមារដទៃទៀតលេងជាមួយព្រះអង្គ ដោយព្រះអង្គដាក់កំណាត់សំពត់មួយផ្ទាំងតូចតាមបែបបទព្រះសង្ឃតែងប្រើទទួលនូវការប្រគេនផ្សេងៗ។

សមាជិកគ្រួសារវង្សសាវាង និង គជវត្រ តែងនិយាយថា “សម្តេចបានបួសតាំងពីវ័យកុមារម្ល៉េះ ហើយពួកគេតែងតែរំលឹករឿយៗនូវល្បែងដើរតួជាព្រះសង្ឃ ដែលសម្តេចចូលចិត្តលេង ”។

ក្នុងកិច្ចការប្រចាំថ្ងៃ ម្តាយធំ គីមហេង តែងក្រោកពីព្រលឹមចេញទៅធ្វើការងារ កុមារ “ច្រើន” ក៏តែងតែមានទម្លាប់ក្រោកពីព្រលឹមដែរ”។ មុនពេលចាកចេញពីផ្ទះម្តាយធំ គីមហេង តែងតែអនុជទៀនឲ្យកុមារនេះលេងជាមួយ។ សម្តេចតែងតែអង្គុយមើលអណ្តាតភ្លើងរហូតដល់ពេលអរុណរះនិងមានពន្លឺព្រះអាទិត្យដំបូងផុសចេញពីជើងមេឃ។

ក្រលេកមើលអតីតកាល យើងមានភាពច្បាស់លាស់ក្នុងចិត្តថា សកម្មភាពទាំងនោះជាប្រផ្ចិលសបញ្ជាក់ថា សម្តេចនឹងបួជាជីវិតទ្រទ្រង់

នូវសំពត់កាសាវភ័ស្ត្រជាភិក្ខុសង្ឃ។

សម្តេចមានហឫទ័យទន់ភ្លន់និងអាកប្បកិរិយាសុភាពរាបសារ ព្រះអង្គមិនដែលខឹលខួចឡើយ។ ក្នុងនាមជាកូនច្បង ព្រះអង្គបានមើលថែប្អូនៗនិងកុមារផ្សេងទៀតក្នុងគ្រួសារ។

នៅអាយុប្រាំបីឆ្នាំ ព្រះអង្គបានទៅសិក្សានៅសាលាក្នុងវត្តទេវសង្ឃារាម ជិតនោះ។ ព្រះអង្គបានបញ្ចប់ថ្នាក់បឋមសិក្សានៅអាយុ ១២ ឆ្នាំ ក្នុងឆ្នាំ ១៩២៥។

ពេញមួយវ័យកុមារភាព សម្តេចបានទទួលនៅភាពកក់ក្តៅពីក្រុមគ្រួសារដ៏ជិតស្និទ្ធ និងជីវិតជនបទសាមញ្ញដែលចិញ្ចឹមបីបាច់ព្រះអង្គឲ្យមានសេចក្តីករុណា ខន្តី និងភាពស្មោះត្រង់។ គុណភាពទាំងនេះបានបណ្តុះនូវភាពលូតលាស់ផ្លូវធម៌ (សច្ចធម៌ផ្លូវចិត្ត) ក្នុងសន្តាន និងបានផលិតនូវគ្រួផ្លូវចិត្ត និងទស្សនវិជ្ជាដ៏ខ្លាំងក្លាមួយអង្គ ដែលមានករុណាគ្របដណ្តប់លើបេះដូងនៃមនុស្សជាច្រើនទូទាំងពិភពលោក។ កុមារតូចនេះបានក្លាយជា"សម្តេចព្រះញាណសំវរ ព្រះសង្ឃរាជទី១៩នៃព្រះរាជាណាចក្រថៃ" ។

1952 His Hiliness was attending Relics celebration celemony at Preah Vihear Preah Keo Morakot in Cambodia

ជីវិតថែរក្សាដោយព្រះធម៌

"ព្រះធម៌ (សច្ចធម៌ផ្លូវចិត្ត) គឺជារតនៈវត្ថុដ៏មានតម្លៃពិព្រោះព្រះធម៌គ្មានភាពសៅ ហ្មងនិងមានប្រយោជន៍។ គ្មានអ្វីដែលឥតប្រយោជន៍នោះទេនៅក្នុងព្រះធម៌។ ព្រះពុទ្ធបានបង្ហាញនូវព្រះធម៌តាមរយៈពាក្យប្រៀនប្រដៅរបស់ព្រះអង្គ។ ព្រះធម៌គឺជាវិន័យជាក្រិត្យក្រមមានលំដាប់លំដោយ ដែលសង្គ្រោះចូលនូវរាល់ផ្នែកទាំងឡាយនៃជីវិត ព្រះធម៌គឺជាប្រទីបដែលបំភ្លឺនូវសច្ចធម៌គ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង។ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គផ្តល់នូវជីវជាតិត្រឹមត្រូវនិងគ្រប់គ្រាន់ដល់មនុស្សគ្រប់ៗគ្នា"។

(គោលធម៌គ្រឹះពុទ្ធសាសនា)

សម្តេចព្រះសង្ឃរាជ ព្រះញាណសំវរ បានបោះបង់ជីវិតឃរាវាសឆ្ពោះមករកផ្លូវព្រះធម៌នៅពេលព្រះអង្គមានព្រះជន្ម១៤ព្រះវស្សា។

ក្នុងឆ្នាំ១៩២៦ ខណៈពេលដែលឪពុកមាតាពីរនាក់របស់ព្រះអង្គឈ្មោះ ថែម និង ចុងលី ជិតចូលសាងផ្នួសនៅវត្តទេវសង្ឃារាម មាតានិងម្តាយធំរបស់ព្រះអង្គបានជំរុញអោយព្រះអង្គចូលសាងផ្នួសជាសាមណេរ ដើម្បីបំពេញពាក្យសច្ចាដែលបានធ្វើច្រើនឆ្នាំកន្លងមកហើយ ដើម្បីលាបំណន់ដែលបានបួងសួងសុំឲ្យព្រះអង្គជាសះស្បើយពីជំងឺជាច្រើនឆ្នាំកន្លងមកហើយ។ ដោយសារព្រះអង្គទើបបានបញ្ចប់បឋមសិក្សានៅពេលហ្នឹងផង ព្រះអង្គក៏យល់ព្រម។

ព្រះឧបជ្ឈាយ៍របស់សម្តេចគឺៈព្រះគ្រូអទុល្យសមណកិច្ច(ឪពុទ្ធជោតិ)ដែលត្រូវបានគេស្គាល់ជាទូទៅថា"លោកឪវត្តណី"ជាព្រះចៅអធិការវត្តទេវសង្ឃារាម។ ព្រះគ្រូ និវិតសមាចារ្យ (ង៉ែន សុវណ្ណជោតិ) ព្រះចៅអធិការវត្តស្រីឧបលារាម បានផ្តល់ត្រៃ សរណគមន៍ដល់កុមារ "ច្រើន" ដែលជាវិធីផ្តល់នូវព្រះរតនត្រ័យ (ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ)។ បន្ទាប់មកត្រូវទទួលសីល ដែលជាសិក្ខាបទបែបសីលធម៌ព្រះពុទ្ធសាសនា។

ចាប់ពីខណៈនេះក្នុងជីវិតរបស់ព្រះអង្គ សម្តេចបានបដិបត្តិតាមផ្លូវព្រះធម៌ហើយមិនដែលត្រឡប់ទៅជាជីវិតឃរាវាសឡើយ។

ក្នុងកំឡុងឆ្នាំទីមួយជាសាមណេរ សម្តេចបានប្រឹងរៀនសូត្រនិងអនុវត្តនូវអ្វីដែលព្រះអង្គបានរៀនរួមទាំងការសូត្រធម៌ផងដែរ។ ព្រះអង្គបានគាល់បម្រើគ្រូរបស់ព្រះអង្គគឺលោកឪឌី។ នៅពេលយប់ លោកឪបានសូត្រធម៌និងបង្គាប់ឲ្យសាមណេរអង្គនេះទន្ទេញព្រះធម៌ទាំងអស់។ លោកឪបានសូត្រមួយផ្នែកនិងបន្ត

ងៀងរាល់យប់រហូតបញ្ចប់ជំពូកទាំងមូល។ វិធីសាស្ត្របង្រៀនព្រះធម៌បែបប្រពៃណីនេះត្រូវបានអនុវត្តតាំងតែពីបូរាណកាលមក។

អរិយធន: (រតន:វត្ថុដ៏ប្រសើរ) គឺជាជំពូកទីមួយដែលលោកឪបានបង្រៀនដល់សម្តេច ហើយព្រះអង្គបានទន្ទេញចាំមាត់នៅក្នុងរយៈពេលដ៏ខ្លី។ បន្ទាប់ពីបានចេះចាំនូវវិធីសាស្ត្រ ព្រះអង្គអាចសម្តែងព្រះធម៌ទេសនានៅក្នុងឆ្នាំដំបូងនៃជីវិតផ្នួសរបស់ព្រះអង្គ។ ព្រះអង្គបានសម្តែងយ៉ាងរលូនប្រកបដោយភាពជឿជាក់។ គ្រប់ពាក្យនៃការសម្តែងព្រះធម៌របស់ព្រះអង្គត្រូវបានកត់ត្រាទុកនៅក្នុងទិវានុប្បវត្តន៍ផ្ទាល់ខ្លួនរបស់ព្រះអង្គ។

ទោះបីព្រះអង្គបានចាំផ្តើមជីវិតជាសាមណេរដោយមូលហេតុណាបំណន់ដែលបានធ្វើឡើងដោយញាតិរបស់ព្រះអង្គក៏ដោយ ក៏ព្រះអង្គបន្តទ្រទ្រង់ព្រះពុទ្ធសាសនាដោយសុទ្ធចិត្តនិងបានចំរុងចម្រើនជាភិក្ខុមួយអង្គ។ ក្នុងឆ្នាំ១៩២៧ លោកឪឪីបានបញ្ជូន សាមណេរ “ច្រើន” ឲ្យទៅសិក្សាភាសាបាលីជាមួយព្រះគ្រូ សំវរវិន័យ (អាច) ព្រះចៅអធិការវត្តសែនហា ក្នុងខេត្តនគរបឋម”។ លោកឪឪីបានសម្រេចថាសាមណេរ ច្រើនត្រូវតែហ្វឹកហ្វាត់ឲ្យក្លាយជាគ្រូ។ បន្ទាប់មកលោកឪឪីបានកសាងសាលាព្រះបរិយត្តិធម៌ ខណៈពេលរង់ចាំសិស្សព្រះអង្គត្រឡប់ពីសិក្សាវិញ។

ការរស់នៅឆ្ងាយពីស្រុកកំណើតមិនមែនជាការរស់នៅឯកោនោះទេ ព្រោះសម្តេចបានសាងមិត្តជាច្រើនយ៉ាងលឿន។ ព្រះអង្គបានបន្តមិត្តភាព ដែលព្រះអង្គបានសាងជាមួយនឹងភិក្ខុសាមណេរមួយចំនួននៅវត្តសែនហា។ មានរូបថតសប្បាយរីករាយនិងពេលផលាដែលនៅរួមគ្នាត្រូវបានសរសេរដាក់ចំណងជើងយ៉ាងត្រឹមត្រូវនិងរក្សាទុកនៅក្នុងកម្រងរូបថត (Album)។

ក្នុងខណៈជាសិស្សមួយរូបនៅវត្តសែនហា សម្តេចបានទទួលលទ្ធផលសិក្សាល្អ ណាស់រហូតដល់ព្រះមហាធាក់សាក់ឆ្លើមណែនាំឲ្យព្រះអង្គចុះឈ្មោះរៀនក្នុងកម្មវិធីជាន់ខ្ពស់នៅវត្តមកុដកប្បត្រិយារាម។ ព្រះមហាធាក់សាក់ឆ្លើមគឺជាបញ្ញាវន្តមួយអង្គក្នុងវត្តមកុដកប្បត្រិយារាមក្នុងទីក្រុងបាងកក ដែលបានលើកទឹកចិត្តសម្តេចឲ្យប្រព្រឹត្តតាមគន្ធងរបស់ព្រះអង្គ។ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយលោកឪឪី សម្តេចក៏ត្រូវណែនាំឲ្យបន្តការសិក្សាជាន់ខ្ពស់នៅវត្តមួយផ្សេងទៀតក្នុងទីក្រុងបាងកក គឺវត្តបវរនិវេសវិហារដែលស្ថិតនៅជិតទឹកន្លែងគង់នៅដើមរបស់លោកឪឪី។ សម្តេចក៏មានទំនាក់ទំនងជិតស្និតជាមួយសម្តេចក្រុមហ្លួង វជិរញ្ញាណវង្ស ព្រះសង្ឃរាជទី១៣ ដែលលោកឪឪីធ្លាប់ស្គាល់ច្រើនឆ្នាំមកហើយ។ បន្ទាប់ពីសិក្សាមួយឆ្នាំនៅវត្តសែនហាសម្តេចបានអមដំណើរគ្រូព្រះអង្គទៅវត្តបវរនិវេសវិហារ ក្នុងឆ្នាំ១៩២៩ លោកឪឪីនឹងសម្តេចកាលនៅជាសាមណេរច្រើនបានជិះរទេះភ្លើងធ្វើដំណើរពីខេត្តកញ្ចនបុរីឆ្ពោះទៅទីក្រុងបាងកក។

សម្តេចព្រះសង្ឃរាជទី១៣ ដែលបានទទួលគោរមងារជាសម្តេចព្រះវជិរញ្ញាណវង្ស ជាព្រះចៅអធិការវត្តបវរនិវេសរាជវរារាម។ ព្រះសង្ឃរាជទី១៣ព្រមទទួលសម្តេចឲ្យគង់នៅក្នុងវត្ត ដោយអនុលោមតាមសំណូមពររបស់លោកឪឪី។

ពេញមួយថ្ងៃដំបូងនៃការស្នាក់នៅវត្តបវរនិវេស សម្តេចបានគោរពតាមច្បាប់និងបទបញ្ជាផ្ទៃក្នុងទាំងអស់យ៉ាងខ្ជាប់ខ្ជួន ដែលជាហេតុធ្វើអោយព្រះចៅអធិការផ្តល់នូវនាមថ្មី “សុវឌ្ឍនោ - អ្នកចំរើន” ដល់ព្រះអង្គ។

នៅស្ថាប័នសិក្សាជាន់ខ្ពស់នេះ ក្នុងចំណោមព្រះសង្ឃទាំងឡាយ សម្តេចមានការលូតលាស់ចម្រើនពេញលេញ។ ព្រះអង្គបានសិក្សាដោយការយកចិត្តយ៉ា

ងខ្លាំងនិងបានបញ្ចប់ថ្នាក់ទីបីនៃធម្មវិន័យនិងថ្នាក់ទីបួននៃការសិក្សាភាសាបាលី (ការសិក្សាភាសាបាលីមានប្រាំបួនកម្រិត) នៅវស្សាទីប្រាំបី ព្រះអង្គបានត្រឡប់ទៅខេត្តកញ្ចនបូរីវិញ ហើយបានស្នើព្រះឧបជ្ឈាយ៍របស់ព្រះអង្គនៅវត្តទេវសង្ឃារាមឲ្យជួយបំបួសព្រះអង្គ ជាភិក្ខុភាវៈ។

ក្រោយបួសជាភិក្ខុភាវៈរួចហើយ ដែលនៅចំរដូវចូលព្រះវស្សាបីខែ សម្តេចបានគង់នៅជាមួយព្រះឧបជ្ឈាយ៍ព្រះអង្គ ដើម្បីជួយបង្ហាត់ព្រះធម៌នៅសាលាធម្មវិន័យដែលទើបបើកថ្មីតាមបំណងប្រាថ្នារបស់គ្រូ។

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៣៣ សម្តេចបានត្រឡប់ទៅវត្តបវរនិវេសក្នុងទីក្រុងបាងកក ដើម្បីបួសជាភិក្ខុភាវៈឡើងវិញដោយសម្តេចព្រះសង្ឃរាជទី១៣។ ព្រះតេជ ព្រះគុណ រតនធជមុនី (ជូ ឥស្សរញ្ញាណោ) គឺជាគ្រូសូត្រធ្យរបស់សម្តេច។ ចាប់ពីថ្ងៃនោះមក សម្តេចដែលត្រូវបានគេស្គាល់តាមឈ្មោះបួសថ្មីថា ភិក្ខុសុវឌ្ឍនោ បានបួសពេញមួយជីវិតរបស់ព្រះអង្គក្នុងព្រះធម៌ ដែលជាក្រសែជីវិតមួយដែលព្រះអង្គបានទ្រទ្រង់ដោយសុទ្ធចិត្ត។ វាក៏ជាឧបនិស្ស័យមួយដែលផ្តល់ផលដល់សង្គមយ៉ាងច្រើនមហិមា។ការបូជាពេញមួយជីវិតចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ បានធានាឲ្យសម្តេចមានការប្រព្រឹត្តខ្ជិនលំទោន សុភាពរាបសារ គោរពដល់ឱវាទគ្រូបាអាចារ្យ និងឧបដ្ឋាកៈទាំងឡាយរបស់ព្រះអង្គ។ ថែទាំដោយព្រះធម៌និងសក្តិសមទៅនឹងអត្ថន័យនៃនាមបញ្ញត្តិរបស់ព្រះអង្គ ចរិករបស់ព្រះអង្គមានការរីកចម្រើននិងពេញលក្ខណៈបរិបូណ៌។



"ការធ្វើធម្មទានពិតគឺការភ្ជាយជាព្រះធម៌ដោយខ្លួនឯង ចម្រើនធម៌ឲ្យកើតឡើងដោយស្ម័យប្រវត្តិនៅក្នុងខ្លួនឯងនិងអ្នកដទៃ។ ពាក្យប្រៀនប្រដៅមិនមានការចាំបាច់ត្រូវបង្ហាញតាមរយៈពាក្យសំដី ការទេសនា ឬការអធិប្បាយឡើយ" ។

(ធម្មទានឈ្នះអស់ទានទាំងពួង)

"ការបតិបត្តិព្រះធម៌រហូតដល់កាយនិងចិត្តរបស់ខ្លួនភ្ជាយជាសភាវៈតែមួយជាមួយនឹងព្រះធម៌ គឺជាការប្រកាសព្រះធម៌ដ៏ល្អឥតខ្ចោះ ទាំងអ្នកឈរមើលទាំងអ្នកស្ងៀងកេ។ វិធីបែបនេះមានប្រសិទ្ធភាពច្បាស់លាស់ជាងការសរសេរសៀវភៅ" ។

(ធម្មទានឈ្នះអស់ទានទាំងពួង)

ព្រះសង្ឃដែលស្រលាញ់ការអប់រំ

"ទី១ និងសំខាន់បំផុត ការអប់រំគឺជាការបណ្តុះចំណេះវិជ្ជានិងជំនាញសម្រាប់ធ្វើការនិងរស់នៅក្នុងសង្គម។ ទី២ ដើម្បីបន្តគុណភាពមនុស្ស។ កម្មវត្ថុទី១ គឺវាមានលក្ខណៈធ្លាស់លាស់ណាស់។ កម្មវត្ថុទី២ គឺមានន័យថាការកើតជាមនុស្ស ការបានទ្រវាងកាយជាមនុស្សមិនទាន់គ្រប់គ្រាន់ជាមនុស្សពិតប្រាកដទេ។ នៅពេលណាមនសិការត្រូវបានរួមបញ្ចូលដោយត្រឹមត្រូវឬផ្សំបញ្ចូលជាមួយដោយបុគ្គលិកលក្ខណៈពេលនោះមនុស្សភាវៈនឹងកើតឡើយពិតប្រាកដ។ នៅពេលបុគ្គលណាមានមនុស្សធម៌ពិតប្រាកដ បុគ្គលនោះអាចហៅបានថា "មនុស្ស"។

(គោលធម៌គ្រឹះពុទ្ធសាសនា)







ដោយមានចំណង់ចំណូលចិត្តខាងផ្នែកស្រាវជ្រាវ សម្តេចមានការតស៊ូព្យាយាមរៀនសូត្រភាសានិងចំណេះដឹងផ្សេងៗ ព្រមទាំងជាអ្នកប្រតិបត្តិនូវព្រះធម៌យ៉ាងខ្ជាប់ខ្ជួន។ បុគ្គលិកលក្ខណៈទាំងអស់នេះមានប្រយោជន៍យ៉ាងធំធេងណាស់សម្រាប់សកម្មភាពរបស់ព្រះអង្គក្នុងពេលអនាគត។

ស្ថិតនៅលើផ្លូវទៅកាន់ភាពភ្លឺថ្លារុងរឿងសាមណេរច្រើនមានភ័ព្វសំណាងណាស់ដោយមានគ្រូល្បីៗជាច្រើនដែលមានឥទ្ធិពលមកលើការរីកចម្រើនផ្លូវចិត្តនិងភាពពេញលក្ខណៈ។ ខណៈពេលព្រះអង្គកំពុងសិក្សាជាសាមណេរនៅវត្តបវរនិវេស សម្តេចព្រះវជិរញាណវង្ស (ព្រះសង្ឃរាជទី១៣) បានប្រទុកប្រដាក់សម្តេចវ័យក្មេងនេះឲ្យព្រះគ្រូពុទ្ធមន្តប្រិយ៍ជាមើលការខុសត្រូវ។ សម្តេចដែលពេលក្រោយមកត្រូវបានគេស្គាល់ថា ភិក្ខុសុវឌ្ឍនោ បានពោលអំពីគ្រូរបស់ព្រះអង្គថាជាបុគ្គលសុភាពរាបសារនិងចិត្តល្អ ប៉ុន្តែក៏ជាបុគ្គលយល់ច្បាស់លាស់នូវអ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ។ ព្រះគ្រូពុទ្ធមន្តប្រិយ៍ជា ជាអ្នកគ្រប់គ្រងដ៏មានសមត្ថភាពនិងប្រសិទ្ធភាព ក្នុងការដឹកនាំភិក្ខុសាមណេរក្រោមឱវាទរបស់ព្រះអង្គ។ ព្រះអង្គមានសុភវិនិច្ឆ័យ ប្រសិនបើព្រះអង្គមានការសង្ស័យពីសមត្ថភាពនរណាមួយព្រះអង្គមិនស្ទាក់ស្ទើរដកចេញនូវការទទួលខុសត្រូវមកវិញដោយខ្លាចមានផលប៉ះពាល់ដល់សិស្ស។ ទោះបីជាមានភាពតឹងរឹងជាមួយសិស្សគណៈ ព្រះអង្គមានភាពរហ័សរហួនក្នុងការជួយសម្រួលនិងលើកទឹកចិត្តឲ្យសិស្សទទួលបានជោគជ័យ។

សម្តេចព្រះវជិរញាណវង្សចូលចិត្តសាមណេរច្រើន សុវឌ្ឍនោ និងបានបង្រៀនវិជ្ជាជាច្រើនដល់ព្រះអង្គផ្ទាល់។ វិធីបង្រៀនរបស់ព្រះអង្គមានភាពទាក់ទាញណាស់ដែលធ្វើឲ្យសាមណេរមានការព្យាយាម ចេះវិភាគស្រាវជ្រាវនិងត្រិះរិះពិចារណា។ សម្តេចបានក្លាយជាគ្រូសមាធិលើកដំបូងរបស់សាមណេរនេះ។ នៅពេលសាមណេរមកដល់វត្តបវរនិវេសដំបូង សម្តេចបានហៅសាមណេរអង្គនេះទៅកុដិរបស់ព្រះអង្គហើយពោលថា “ខ្ញុំកុណាឮថាព្រះអង្គតស៊ូព្យាយាមណាស់ ប៉ុន្តែកុំសិក្សាតែម្យ៉ាង រកពេលធ្វើសមាធិខ្លះផងទៅ”។

សម្តេចព្រះញាណសំវរមានការគោរពកោតក្រែងនិងការស្រឡាញ់ដោយស្មោះចំពោះគ្រូរបស់ព្រះអង្គទាំងអស់ និងគោរពប្រតិបត្តិគ្រូទាំងនោះជាគំរូសម្រាប់ជីវិតព្រះ អង្គ។

ទោះបីជាមានសុខភាពមិនសូវល្អ សម្តេចមានការរីកចម្រើនខ្លាំងនិងទទួលជោគ ជ័យយ៉ាងត្រចះត្រចង់ក្នុងការសិក្សា។ ដោយបានប្រើប្រាស់ផ្លូវចិត្តជាជាងផ្លូវកាយក្នុងការស្វែងរកនូវការអប់រំ ព្រះអង្គបានយកឈ្នះលើសុខភាពទន់ខ្សោយរបស់ព្រះអង្គពេលខ្លះនៅពេលមានអាពាធ សម្តេចមិនសឹងនៅមួយកន្លែងទេ ហើយព្រះអង្គរុំកំណាត់ដាមសត្វក្រាស់ព័ទ្ធជុំវិញទ្រូងដើម្បីឲ្យកក់ក្តៅ ហើយបន្តការសិក្សានិងធ្វើលំហាត់ផ្សេងៗ។

នៅឱកាសមួយនោះនៅពេលព្រះអង្គប្រឈងធ្ងាក់បាលីប្រយោគបួន ព្រះអង្គមានអារម្មណ៍មិនសប្បាយនិងតូចចិត្ត។ នៅពេលពិចារណាគ្រប់ជ្រុងជ្រោយ ព្រះអង្គបានសន្និដ្ឋានថា ការបរាជ័យនោះពីព្រោះតែមោទនភាពខ្លាំងនឹងចំណេះដឹងរបស់ខ្លួន ដែលបានរារាំងមិនឲ្យទទួលបាននូវគំនិត ការត្រិះរិះនិងការរៀនសូត្រថ្មី។ ព្រះអង្គបានសិក្សាហើយព្រះអង្គបានប្រឡងជាលើកទីពីរ ដោយតាំងចិត្តមិនឲ្យមានកំហុស



ដូចលើកមុនជាថ្មីម្តងទៀតឡើយ។ ដោយមានផ្នត់គំនិតកែប្រែនិងបានឧស្សាហ៍ព្យាយាមព្រះអង្គបានសម្រេចជោគជ័យក្នុងការសិក្សាភាសាបាលីប្រយោគប្រាំបួនក្នុងឆ្នាំ១៩៤១។

ចាប់ពីពេលដែលព្រះអង្គបានបញ្ចប់ការសិក្សាភាសាបាលីប្រយោគប្រាំសម្តេចបានបង្រៀនព្រះធម៌និងភាសាបាលីនៅវិទ្យាស្ថានវត្តបវរនិវេសវិហារព្រះអង្គបាន សិក្សាភាសាបាលីប្រយោគ៦-៧ ដោយខ្លួនឯង ក្នុងឆ្នាំ១៩៣២។ ក្នុងឆ្នាំនោះដែរ សាស្ត្រាចារ្យ ស្វាមីសត្យនន្ទបុរី ជេទន្តប្រទីប អ្នកជំនាញ

ជនជាតិឥណ្ឌាផ្នែកសាសនាហិន្ទូ សំស្ក្រឹត និងអង់គ្លេស បានបើកមជ្ឈមណ្ឌលផ្លាស់ប្តូរការអប់រំមួយមានឈ្មោះថាធម្មាស្រម នៅទល់មុខវត្តបវរនិវេស។ អស់រយៈពេលជាងពីរឆ្នាំ ព្រះអង្គបានចំណាយពេលវេលាយ៉ាងច្រើនតាមដែលព្រះអង្គអាច ក្រៅពីបង្រៀនភាសា ដើម្បីរៀនសូត្រពីស្វាមីសត្យនន្ទបុរី។

កំឡុងពេលនេះបានក្លាយជាមូលដ្ឋានគ្រឹះនិងការចាប់ផ្តើមការអប់រំដោយខ្លួនឯងរបស់ព្រះសម្តេច។ តាមរយៈស្វ័យសិក្សានេះព្រះអង្គបានទទួលនូវជំនាញភាសា អង់គ្លេស អាចនិយាយ អាន សរសេរ យ៉ាងរលូន។ ព្រះអង្គបានបន្តការសម្រេចភាពជោគជ័យនេះ ដោយការចូលចិត្តលើការសិក្សាភាសាផ្សេងៗទៀតដូចជា អាល់ឡឺម៉ង់ បារាំង និងចិន។ ជំនាញភាសារបស់ព្រះអង្គរួមផ្សំនិងគំនិតចង់ស្វែងយល់ បានជួយអភិវឌ្ឍភាពមុតស្រួចខាងបញ្ញាញាណ ដែលអាចឲ្យព្រះអង្គសង្ខេបពន្យល់និង ផ្សព្វ ផ្សាយព្រះធម៌បាន។ ព្រះអង្គអាចបញ្ចេញទស្សនៈយ៉ាងរលូននិងប្រកបដោយប្រសិទ្ធភាព នៅពេលបង្រៀននិងសរសេរសៀវភៅជាច្រើន ទាំងភាសាថៃនិងភាសាបរទេស។

ការសិក្សាភាសារបស់ព្រះអង្គត្រូវបានអាក់ខាននៅពេលដែលព្រះអង្គទទួលយកតួនាទីក្នុងការទទួលខុសត្រូវច្រើនឡើងៗ ក្នុងឋានៈជាអ្នកអប់រំផ្នែកព្រះពុទ្ធសាស នា។

- ឧទាហរណ៍ នៅឆ្នាំ១៩៤១ ព្រះអង្គបានក្លាយជានាយកវិទ្យាស្ថានវត្តបវរនិវេសវិហារ ដែលត្រូវត្រួតពិនិត្យកម្មវិធីសិក្សាសម្រាប់ភិក្ខុសាមណេរទាំងឡាយ។

ក្នុងឆ្នាំ១៩៤៥ ព្រះអង្គបានក្លាយជាគ្រូក្នុងពុទ្ធិកសាកលវិទ្យាល័យមហាមកុដនិងជាសមាជិកក្រុមប្រឹក្សាអប់រំ។ នៅឆ្នាំដដែលនោះ ព្រះអង្គបានក្លាយជាសមាជិកថេរៈសភាសង្ឃនៃគណៈសង្ឃជាន់ខ្ពស់ថៃ (មហាថេរៈសមាគម)។

ក្នុងកំឡុងពេល២០ឆ្នាំ ព្រះអង្គបានបង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ព្រះសង្ឃ។ ព្រះអង្គបានគាំទ្រកម្មវិធីអាហារូបករណ៍សម្រាប់ភិក្ខុសាមណេរដែលរួមបញ្ចូលនិស្សិតជាគ្រូហស្តមួយចំនួនធំ នៅតាមវិទ្យាស្ថានានា។

ទោះបីជាព្រះអង្គបានគង់ក្នុងជីវិតពេញវ័យភាគច្រើនក្នុងទីក្រុងក៏ដោយ សម្តេចអាចរកពេលដើម្បីដឹកនាំជីវិតវិវេកដែលបានផ្តល់ភាពងាយស្រួលដល់ការចម្រើនសមាធិនិងការបដិបត្តិផ្លូវចិត្ត។ ព្រះអង្គបានទទួលយកព្រះសង្ឃរាជទី១៣ សម្តេចក្រុម ហ្លួងព្រះជីរញ្ញាណវង្ស ជាគំរូនៃការបដិបត្តិវិន័យនិងឥន្ទ្រិយ៍សំវរ។ ព្រះអង្គតែងតែមានសតិគ្រប់ពេលវេលានិងស្រាវជ្រាវព្រះធម៌យ៉ាងយកព្រះទ័យទុកដាក់ ទាំងផ្នែកទ្រឹស្តីនិងការបតិបត្តិ។

ព្រះអង្គតែងធ្វើដំណើរទៅសួរសុខទុកភិក្ខុសង្ឃអង្គនានាដែលជាគ្រូសមាធិធំៗ។

ព្រះអង្គតែងធ្វើដំណើរទៅសំណាក់អង្គដទៃដែលជាគ្រូសមាធិធំៗ ក្នុងគោលបំណងដើម្បីស្វែងយល់នូវព្រះធម៌ដែលគ្រូសមាធិទាំងនោះបានរៀ

ននិងចេះចាំមក ព្រះអង្គមានចំណាប់អារម្មណ៍ខ្លាំងចំពោះគ្រូសមាធិនៅប្រទេសថៃភាគខាងជើង។ ព្រះអង្គបានធ្វើដំណើរទៅកាន់សំណាក់ព្រះតេជគុណ ហ្វាន់ អាចារោ, ព្រះតេជគុណ ដុល អាតុលោ, ព្រះតេជគុណ ខាវ អានាលយោ, ព្រះតេជគុណ ធេស ទេសរង្សី, ព្រះតេជគុណ ប៊ូរ ញាណសម្បន្នោ, ព្រះតេជគុណ ភុត ថានិយោ ក្នុងចំណោមគ្រូសមាធិទាំងឡាយ។

សម្តេចបាននិមន្តទៅកាន់សំណាក់ព្រះតេជគុណ ជៀន សុចិន្ទោ គង់នៅវត្តដយ មែបាងក្នុងខេត្តឈៀងម៉ៃ។ ព្រះអង្គក៏បាននិមន្តទៅកាន់សំណាក់ព្រះតេជគុណ ពុទ្ធទាស ឥន្ទបញ្ញោ គង់នៅវត្តសួនមោក្ខពលារាម ក្នុងខេត្តសុរដ្ឋធានី ប្រទេសថៃភាគខាងត្បូង។

ចំណង់ចំណូលចិត្តឥតរាថយក្នុងការស្វែងរកនូវចំណេះដឹងនិងការអប់រំខ្លួនបានធ្វើឲ្យព្រះអង្គ ក្លាយទៅជាអ្នកប្រាជ្ញមួយព្រះអង្គគួរជាទីគោរពបំផុតក្នុងប្រទេសថៃ។ ព្រះអង្គមានការយល់ដឹងខាងព្រះធម៌ដែលត្រូវបានមនុស្សម្នាកោតសរសើរថា ជាព្រះសង្ឃមានការបដិបត្តិល្អនិងមានការរីកចម្រើនយ៉ាងត្រចះត្រចង់ក្នុងការស្វែងរកនូវព្រះធម៌។

"ប្រសិនបើបុគ្គលចង់ក្លាយទៅជាអ្នកមានចំណេះដឹង គេត្រូវតែប្រឹងប្រែងសិក្សា"។ ប្រសិនបើបុគ្គលចង់មានទ្រព្យដោយសុចរិតគេត្រូវតែធ្វើការដោយត្រឹមត្រូវនិងម៉ឺងម៉ាត់ ប្រកបដោយលក្ខណៈសមសួន។ តាមរយៈការប្រព្រឹត្តបែបនេះ គេពិតជាបានបដិបត្តិឲ្យមាគ៌ាប្រកបដោយអន្តរាយក្នុងសង្សារវដ្តនេះ"។

(ធម្មទានឈ្នះអស់ទានទាំងពួង)



ការស្វែងរកព្រះធម៌

"នៅពេលដែលបុគ្គលទទួលបានការងារឬគោរម្យងារកាន់តែសំខាន់ គេគប្បីពុះពារកាន់តែច្រើនក្នុងការលើកស្ទួយតំណែងនោះ។ ប្រសិនបើបុគ្គលធ្វើបានដូច្នេះ គេអាចបង្ហាញដល់ពិភពលោកថា គេទទួលយកការងារនោះដោយពិតប្រកដ។ បុគ្គលត្រូវតែស្មោះត្រង់ចំពោះភូមានិងភារកិច្ច របស់ខ្លួន។ នៅពេលបុគ្គលធ្វើបានដូច្នេះ គេនឹងអាចបំពេញនូវការទទួលខុសត្រូវចំពោះអាជីពរបស់គេ"។

(ជីវិតនិងការពិត)

ចាប់ពីថ្ងៃដែលព្រះអង្គបានបួសជាបព្វជិត សម្តេចព្រះញាណសំវរបានឫជាព្រះកាយពលព្រះអង្គក្នុងការអប់រំបែបព្រះធម៌ដើម្បីធ្វើអោយជីវិតមនុស្សដទៃមានការចំរុងចម្រើន។

នៅពេលដែលព្រះអង្គបានបញ្ចប់ការសិក្សាភាសាបាលីប្រយោគ៩សម្តេចបានទ

ទួលតួនាទីនិងភារកិច្ចជាបន្តបន្ទាប់ក្នុងឋានៈជានាយកវិទ្យាស្ថានវត្តបវរនិវេសវិហារ។ប្រសិនបើមានបញ្ហាកើតឡើង ព្រះអង្គបានដោះស្រាយបញ្ហាទាំងនោះជាបន្ទាន់។ ភាពស្ងៀតស្ងាញក្នុងការងារនិងការលះបង់របស់ព្រះអង្គបានធ្វើឲ្យសម្តេចក្រុមហ្លួងវជិរញ្ញាណវង្ស ព្រះសង្ឃរាជទី១៣ មានការជឿជាក់ក្នុងព្រះអង្គ។ សម្តេចព្រះសង្ឃរាជទី១៣តែងតែប្រគល់ការងារសំខាន់ៗដល់ព្រះអង្គ។

ក្នុងឆ្នាំ១៩៤៦ ព្រះអង្គបានក្លាយជាលេខាផ្ទាល់នៃសម្តេចព្រះសង្ឃរាជទី១៣ហើយក៏បានចាប់ផ្តើមនៅដំណាក់កាលមួយដ៏សំខាន់បំផុតក្នុងជីវិតរបស់ព្រះអង្គ ដោយទទួលនូវការងារសព្វសារពើនៅក្នុងគណៈសង្ឃពុទ្ធសាសនា។ ព្រះអង្គក៏បានចូលរួមក្នុងការងារសិក្សាធិការ បានបង្រៀនព្រះធម៌និងវិបស្សនាផងដែរ។ សកម្មភាពទាំងអស់នេះបានជួយព្រះអង្គនៅពេលដែលព្រះអង្គបានក្លាយជាព្រះសង្ឃរាជ។

ទោះបីជាព្រះអង្គត្រូវទទួលការងារច្រើនក៏ដោយសម្តេចបន្តបង្រៀនសិស្សភិក្ខុសាមណេរជាសទ្ធិវិហារិកនិងអន្តេវាសិក ក្នុងគោលបំណង់ឲ្យពួកគេអាចយល់និងគោរពព្រះធម៌ទាំងផ្នែកទ្រឹស្តីនិងផ្នែកផ្លូវចិត្ត។ តាំងពីរជ្ជកាលរាមាទី៤ចូលសាងផ្នួសជាបព្វជិតហើយបានក្លាយជាចៅអធិការវត្តបវរនិវេស គេគិតថាវាជាការងារចម្បងសម្រាប់ព្រះឧបជ្ឈាយ៍នៅវត្តបវរនិវេសនេះ គឺការបង្រៀន ដែលជាការងារអាទិភាពនៅក្នុងប្រតិទិនរបស់សម្តេច ហើយព្រះអង្គមិនដែលផ្ទេរការទទួលខុសត្រូវនេះ ទៅអ្នកដទៃឡើយ ទោះបីជាព្រះអង្គមានការងារច្រើនលើសលប់យ៉ាងណាក៏ដោយ។ ក្នុងកំឡុងរដូវចូលវស្សាពាខែរៀងរាល់ឆ្នាំ ជាពេលដែលមានភិក្ខុសាមណេរបួសថ្មីច្រើនអង្គនៅក្នុងវត្ត ព្រះអង្គតែងតែបង្ហាត់បង្រៀនព្រះធម៌វិន័យ:ពេលមួយម៉ោងរៀងរាល់ថ្ងៃដល់ពួកគេ។ សម្តេចក៏បានបង្រៀនសមាធិជាប្រចាំពេញមួយឆ្នាំ។ ព្រះអង្គបានសំដែងធម៌២ដងក្នុង១ខែនៅក្នុងព្រះវិហារ (ឧបោសថាគារ) និងបានបង្រៀនសមាធិ២ដងក្នុង១សប្តាហ៍។

ព្រះអង្គបានបង្រៀនសមាធិនិងវិបស្សនាដល់ភិក្ខុសាមណេរនិងឧបាសកឧបាសិកាផងដែរ។ ពីរដងក្នុង១សប្តាហ៍ ព្រះអង្គបានសំដែងធម្មទេសនានិងបានដឹកនាំអ្នកស្តាប់ទាំងឡាយឲ្យបដិបត្តិសមាធិ។ ការងារនេះបានក្លាយទៅជាកាលវិភាគជាប្រចាំនៅពេលព្រះអង្គបានក្លាយជាចៅអធិការវត្តបវរនិវេសក្នុងឆ្នាំ១៩៦១។

ក្នុងឆ្នាំ១៩៦៣ សម្តេចត្រូវបានតែងតាំងជាមាជិកគណៈកម្មការប្រតិបត្តិនៃមហាថេរៈសមាគមលើកទី១ យោងតាមសង្ឃប្រកាសឆ្នាំ១៩៦២ និងបានចូលរួមក្នុងការតាក់តែងច្បាប់ស្តីពីការបង្កើតមហាថេរៈ

សមាគមចាប់ពីពេលនោះមក។

សម្តេចមិនត្រឹមតែលះបង់ពេលវេលានិងថាមពលរបស់ព្រះអង្គដើម្បីសុខមាលភាពនិងភាពប្រសើរឡើងនៃគណៈសង្ឃនិងប្រជាជនថៃប៉ុណ្ណោះទេ ប៉ុន្តែដើម្បីសេចក្តីសុខនៃប្រជាជនក្នុងប្រទេសដទៃផងដែរ។ ចាប់តាំងពីឆ្នាំ១៩៦៩ ព្រះអង្គបានដឹកនាំបង្រៀនព្រះធម៌ជាភាសាអង់គ្លេស។ ថ្នាក់ទាំងអស់នេះមានភិក្ខុសាមណេរបរទេសនិង គ្រូហស្តចូលរៀនផងដែរ។ អ្នកស្រី ជូសេបស្វីន ស្តែនតុន ភរិយារបស់អតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសថៃគឺជាសិស្សមួយរូបក្នុងបណ្តាសិស្សទាំងឡាយដទៃទៀត។ សិស្សម្នាក់ទៀតគឺលោកស្រី ចេន ហែមិលថុន មែរិត អ្នកនិពន្ធនិងអ្នករាយការណ៍ជនជាតិអាមេរិក ដែលបានសរសេរសៀវភៅ "ទិនានុប្បវត្តិអ្នកសមាធិ (A Meditator's Diary) ជាសៀវភៅដែលរៀបរាប់ពីបទពិសោធន៍របស់គាត់ក្នុងការចូលរៀនថ្នាក់ព្រះធម៌។សម្តេចគឺជាស្ថាបនិកវិទ្យាស្ថានបណ្តុះបណ្តាលភិក្ខុធម្មទូតនិមន្តទៅបរទេស (Training Institute for Dhammadūta Bhikkhus Going Abroad)។ នៅវត្តបវរនិវេស សម្តេចបានបណ្តុះបណ្តាលព្រះសង្ឃបរទេសឱ្យក្លាយជាគ្រូបង្រៀនព្រះធម៌។សកម្មភាពទាំងនេះបានទាក់ទាញជនបរទេសចំនួនកាន់តែច្រើនឡើងឱ្យចូលចិត្តសិក្សានិងបានទទួលផលពីព្រះធម៌។ សម្រាប់ជាប្រយោជន៍ដល់ជនបរទេសដែលចូលចិត្តទាំងនោះ សម្តេចបានបង្កើតនូវបណ្ណាល័យព្រះពុទ្ធសាសនាជាភាសាអង់គ្លេសនៅក្នុងផ្នែកគណៈសង្ឃអន្តរជាតិក្នុងវត្តបវរនិវេស។

ក្នុងឆ្នាំ១ ៩ ៧ ៣ សម្តេចនៅពេលនោះមានគោរម្យងារជាសម្តេចព្រះញាណសំវរ និងជាអនុប្រធានគណៈគ្រប់គ្រងធម្មយុត្តិកនិកាយ ត្រូវបានជ្រើសតាំងជាតំណាងគណៈគ្រប់គ្រង នៅពេលធ្វើទស្សនកិច្ចទៅកាន់សហគមន៍សង្ឃនិងពុទ្ធសាសនាក្នុងខេត្ត៩ នៃប្រទេសថៃភាគឥសាន។ ក្នុងកំឡុងពេលបំពេញទស្សនកិច្ចបែបនេះដែលមានរយៈពេល១ ០ ថ្ងៃ ព្រះអង្គបានទស្សនាវត្ត សាលារៀននិងការិយាល័យរដ្ឋាភិបាលចំនួន៣ ៧ ហើយបានថ្លែងទៅកាន់ភិក្ខុសាមណេរ សិស្ស មន្ត្រីរាជការ នាយនិងពលទាហាន និងមន្ត្រីប៉ូលីសជាច្រើន។ ប្រជាជនក៏បានមកចូលរួមច្រើនកុះករនៅគ្រប់ទីប្រជុំជននិងកន្លែងដែលព្រះអង្គបាននិមន្តទៅ។ ការថ្លែងរបស់ព្រះអង្គបានជំរុញអោយមានការជ្រះថ្លានិងការចូលចិត្តព្រះធម៌គ្រប់ទីកន្លែងដែលព្រះអង្គនិមន្តទៅផងដែរ។

បន្ថែមទៅលើការបង្រៀនព្រះធម៌សម្តេចក៏បានបង្រៀនសមាធិដល់ជនទាំង ឡាយដែលចូលចិត្ត។

ព្រះអង្គបង្កើតឲ្យមានការភ្ញាក់រលឹកយ៉ាងធំស្តីពីផលប្រយោជន៍នៃសមាធិ ដែលជាវិធីមួយធ្វើឲ្យមានការយល់ដឹងស៊ីជម្រៅក្នុងព្រះធម៌។ ក្នុងឆ្នាំ១៩៧៦ ព្រះអង្គបានយល់ព្រមបង្រៀននៅដេប៉ាតឺម៉ង់ទស្សនវិជ្ជានិងសាសនា នៃសាកលវិទ្យាល័យក្សេតសាស្ត្រ។ មុខវិជ្ជាបង្រៀននោះគេហៅថា “សមាធិតាមបែបព្រះពុទ្ធសាសនា” មានគោលបំណងផ្តល់ការយល់ដឹងស៊ីជម្រៅស្តីអំពីផ្នែកទ្រឹស្តីនិងការបដិបត្តិព្រះធម៌។មុខវិជ្ជាបង្រៀននោះក៏មានគោលបំណងបង្រៀននិស្សិតសាកលវិទ្យាល័យអំពីភាពចាំបាច់និងសារៈសំខាន់នៃកុណានិងមនសិការសមាប្រសង្គម។ សម្តេចក៏បានបង្រៀនសមាធិនៅវិទ្យាស្ថានដទៃទៀត រួមទាំងការិយាល័យរដ្ឋាភិបាលនិងគ្រិះស្ថានឯកជនផងដែរ។ សាលានិងស្ថាប័នជាច្រើនបានទទួលស្គាល់នូវផលប្រយោជន៍នៃសមាធិ និងបានដាក់បញ្ចូលព្រះពុទ្ធសាសនាទៅក្នុងកម្មវិធីសិក្សារបស់គេ។

ក្នុងឋានៈជាប្រធានក្រុមប្រឹក្សាភិបាលមូលនិធិមហាមកុដរាជវិទ្យាល័យក្រោមព្រះរាជូបត្ថម្ភ សម្តេចបានចាត់ចែងអោយមានការបកប្រែគម្ពីរព្រះត្រៃបិដកនិងអត្ថកថាពីភាសាបាលីទៅជាភាសាថៃ។ វាគឺជាសមិទ្ធផលដ៏ធំសម្បើម ព្រោះថានេះគឺជាលើកដំបូងហើយដែលព្រះត្រៃបិដកនិងអត្ថកថាត្រូវបានបកប្រែទាំងស្រុងទៅជាភាសាថៃពីភាសាបាលីដើម។ ច្បាប់ភាសាថៃដំបូងរួមមាន៩១ភាគបានក្លាយជាប្រភពដ៏ស្តុកស្តម្ភក្នុងការចូលរួមវិភាគទានដ៏មានសារៈសំខាន់ចំពោះសាសនសិក្សា និងការផ្សព្វផ្សាយព្រះធម៌។

ការព្យាយាមដោយឥតរាថយរបស់សម្តេចគួបផ្សំនឹងការសរសេរយ៉ាងច្រើននឹងបានជាប្រទីបបំភ្លឺផ្លូវព្រះធម៌សម្រាប់អ្នកដទៃ អស់ពេលជាច្រើនឆ្នាំតទៅមុខ។





“ដើម្បីអោយចិត្តរបស់ខ្លួនផ្សាយពន្លឺដោយក្តីសប្បាយ បុគ្គលត្រូវតែព្យាយាមសម្រេចនូវភាវៈផ្លូវចិត្តនេះដោយខ្លួនឯង។ គ្មានបុគ្គលណាអាចបង្កើតវាសម្រាប់អ្នកទេ។ហេតុដូចម្តេច? គឺដោយការមានសតិ និងដោយសមត្ថភាពអាចដឹងបាននូវការប្រព្រឹត្តនៃចរិតលោភៈ ទោសៈ ម្តមោហៈ។ បុគ្គលត្រូវតែប្រើបញ្ញាប្រឆាំងនឹងផលប៉ះពាល់ដ៏អាក្រក់របស់វា។ កុំអល់ឯក។ វាប្រៀបបានទៅនឹងការទុកឲ្យភ្លើងនេះផ្ទុះរបស់ខ្លួនដូច្នោះដែរ។ បើបុគ្គលអល់ឯកកាន់តែយូរភ្លើងនឹងកាន់តែពិបាកពន្លត់ ហើយការខូចខាតក៏កាន់តែច្រើន”។
(បុណ្យបញ្ញេញ្ញពន្លឺត្រចះត្រចង់)

“លោភៈ ទោសៈ និងម្តមោហៈ នឹងហ៊ុំព័ទ្ធផ្លូវចិត្តបុគ្គលប្រៀបដូចជាញាំងដ៏ក្រាស់និងរឹងមាំដែលចិនចាំងនូវពន្លឺដូច្នោះដែល។ ចិត្តរបស់យើងគួរតែបរិសុទ្ធនិងមានពន្លឺជានិច្ច។ វាគួរឲ្យអស្ចារ្យណាស់ដែលយើងបានប្រើប្រាស់វិធីសព្វបែបយ៉ាងនិងគ្រឿងសៅហ្មងផ្លូវចិត្តជាច្រើនដើម្បីកសាងនូវជញ្ជាំងដ៏ងងឹត
(សម្រាប់ខ្លួនឯង)”។
(បំភ្លឺផ្លូវចិត្ត)

ភ្លឺនផ្អែមផ្សព្វផ្សាយពេញពិភពលោក

”ព្រះពុទ្ធបានបង្រៀនព្រះធម៌នៅទឹកន្លែងដែលមានអារ្យធម្មិចហើយ។ យើងនឹងឃើញថា ពាក្យប្រៀនប្រដៅរបស់ព្រះអង្គមានភាពទាក់ទាញដល់អ្នកបួសដែលបានបដិបត្តិវិបស្សនាវួចហើយ ដែលមានសីល និងបានចម្រើនការអប់រំផ្លូវចិត្តរួចហើយ។អ្នកទាំងអស់នោះមានសេចក្តីសង្ឃឹមដើម្បីច្រួចចាកទុក្ខ។ បើនិយាយអំពីគ្រហស្ថវិញ ព្រះពុទ្ធបានសេពគប់និងអ្នកដឹកនាំមុនគេ ពោលគឺ: ”ព្រះមហាក្សត្រ គហបតី ព្រាហ្មណ៍ និងវិញ្ញូជន”។ នៅពេលមនុស្សទាំងនេះបានយល់ព្រះធម៌ ហើយមានចិត្តគាំងនៅមាំក្នុងព្រះធម៌ មនុស្សផ្សេងទៀតនឹងធ្វើតាម”។

(៤៥ព្រះវស្សានៃព្រះពុទ្ធ)

ក្នុងរយៈពេលជាច្រើនឆ្នាំ សម្តេចព្រះញ្ញាណសំវរ ព្រះសង្ឃរាជ បានព្យាយាមមិនខ្ជាចនឿយហាត់បង្កើតបាននូវមូលដ្ឋានសម្រាប់គោលបំណងដ៏សំខាន់មួយពោលគឺ:ការងាំពូជព្រះធម៌ទូទាំងពិភពលោកដើម្បីឲ្យមនុស្សកាន់តែច្រើនឡើងៗអាចទទួលបាននូវការយល់ដឹងអំពីផ្លូវចិត្ត។ ក្នុងឆ្នាំ១៩៦៦ ក្នុងឋានៈជាប្រធានគណៈកម្មការប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាលភិក្ខុធម្មទូតនិមន្តទៅបរទេស ព្រះអង្គបានទទួលភារៈកិច្ចផ្សព្វផ្សាយព្រះធម៌នៅឯនាយសមុទ្រ។

ព្រះអង្គបានគង់ជាព្រះអធិបតីក្នុងពិធីសម្ពោធវត្តពុទ្ធប្រទីបក្នុងទីក្រុងឡុងដ៏ដែលជាវត្តព្រះពុទ្ធសាសនាថៃដំបូងនៅចក្រភពអង់គ្លេសនិងអឺរ៉ុប។ ព្រះអង្គបានសិក្សាសកម្មភាពសាសនាទាំងឡាយនៅអង់គ្លេសនិងអ៊ីតាលីក្នុងគោលបំណងរក្សានូវសុឆ

ន្ទ:ជាមួយនិងសាសនាដទៃ។ ក្នុងឆ្នាំក្រោយៗមក ព្រះអង្គបាននិមន្តធ្វើទស្សនកិច្ចនៅប្រទេសជាច្រើនដូចជា នេប៉ាល់ ស្រីលង្កា ឥណ្ឌូនេស៊ី អូស្ត្រាលី និងហ្វីលិពីន ដើម្បីបណ្តុះសុឆន្ទ:ផ្នែកសាសនានិងស្វែងយល់អំពីកិច្ចការសាសនាក្នុងប្រទេសទាំងនោះ។

ជាលទ្ធផលនៃការបូជាចំពោះសាសនារបស់សម្តេច ព្រះពុទ្ធសាសនាថេរវាទបានរស់រានឡើងវិញនៅក្នុងប្រទេសជាច្រើន។ ដោយមានការស្នើសុំនិមន្តពីសហគមន៍ពុទ្ធសាសនាជាច្រើនក្នុងប្រទេសឥណ្ឌូនេស៊ីឲ្យនិមន្តទៅផ្សព្វផ្សាយ ព្រះសង្ឃធម្មទូតថៃមួយក្រុមបានប្រឹងប្រែងធ្វើការយ៉ាងយូរដើម្បីឲ្យព្រះពុទ្ធសាសនារស់រានឡើងវិញនៅទីនោះ។ ដើម្បីគាំទ្រនូវសកម្មភាពដ៏បូងៗទាំងនេះ សម្តេចបាននិមន្តទៅធ្វើទស្សនកិច្ចប្រទេសឥណ្ឌូនេស៊ីផ្ទាល់ព្រះអង្គ និងបានធ្វើជាគណ:អធិបតីបំបួសកុលបុត្រឥណ្ឌូនេស៊ីផងដែរ។ វត្តហ្សាការតាធម្មចក្រជ័យសព្វថ្ងៃនេះមានព្រះសង្ឃគង់នៅច្រើនអង្គ ប៉ុន្តែនៅពេលនោះគឺជាវត្តព្រះពុទ្ធសាសនាថេរវាទដំបូងដែលបានកសាងក្នុងប្រទេសឥណ្ឌូនេស៊ីបន្ទាប់ពីរយ:ពេលដ៏ច្រើនឆ្នាំ។ ចាប់ពីពេលនោះមកវត្តពុទ្ធសាសនាថេរវាទច្រើនទៀតត្រូវបានកសាងទូទាំងប្រទេសឥណ្ឌូនេស៊ីហើយគេអាចនិយាយបានថា សម្តេចបានធ្វើឲ្យព្រះពុទ្ធសាសនាមានជីវិតថ្មីឡើងវិញក្នុងប្រទេសឥណ្ឌូនេស៊ី។

នេប៉ាល់គឺជាប្រទេសមួយទៀតដែលសម្តេចបានជួយបង្កើតឡើងវិញនូវគណ:សង្ឃព្រះពុទ្ធសាសនា ព្រះអង្គបានផ្តល់អាហារូបករណ៍ដល់ភិក្ខុសាមណេរនេប៉ាល់ដើម្បីឲ្យពួកគេបានសិក្សាព្រះពុទ្ធសាសនាក្នុងប្រទេសថៃ។ ក្រោយពីបញ្ចប់ការសិក្សាពួកគេបានត្រឡប់ទៅប្រទេសនេប៉ាល់ និងបានជួ

1993 : Jiang Zemin, President of the People›s Republic of China welcome His Holiness at Nanhai Presidential Palace, Beijing, China.

យប្រតិស្ថានព្រះពុទ្ធសាសនាថេរវាទក្នុងទឹកដីកំណើតរបស់ពួកគេ។ ភិក្ខុសាមណេរនេប៉ាល់ច្រើនអង្គទៀតបាននិមន្តមកប្រទេសថៃហើយត្រូវបានសម្តេចលើកទឹកចិត្តឲ្យបង្កើតឡើងវិញនូវការសាងផ្នួសជាប្រវត្តិសាស្ត្រនៃជនជាតិនេប៉ាល់អំបូរសាក្យៈ។ ដូច្នេះហើយ ការបប្រតិស្ថានឡើងវិញនូវព្រះពុទ្ធសាសនាថេរវាទក្នុងប្រទេសនេប៉ាល់ត្រូវបានអនុវត្តដោយស្ទើរតែមិនពិបាកប្រឹងប្រែងប៉ុន្មានទេ។ ក្នុងឆ្នាំ១៩៩៣ សម្តេចបានក្លាយជាមេដឹកនាំសាសនាដំបូងដែលរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិននិមន្តធ្វើទស្សនកិច្ចផ្លូវការទៅកាន់ប្រទេសចិន។

ក្នុងឆ្នាំ១៩៩៨ ព្រះអង្គបានចូលរួមសន្និសីទផ្សព្វផ្សាយព្រះពុទ្ធសាសនាពិភពលោកលើកទី១ក្នុងប្រទេសជប៉ុន។ សន្និសីទលើកទី២និងលើកទី៤ ត្រូវបានប្រារព្ធឡើងក្នុងប្រទេសថៃក្នុងឆ្នាំបន្តបន្ទាប់។

សម្តេចបាននិមន្តធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិក ឥណ្ឌា នេប៉ាល់ កាណាដា អូស្ត្រាលី និងប្រទេសជាច្រើនទៀតនៅអឺរ៉ុប។ សហគមន៍ព្រះពុទ្ធសាសនាក្នុងប្រទេសទាំងនោះមានការលើកទឹកចិត្តដោយមានវត្តមានរបស់ព្រះអង្គក៏បានកសាងវត្តច្រើនថែមទៀតដូចជាវត្តពុទ្ធរង្សីក្នុងប្រទេសអូស្ត្រាលី, វត្តការ៉ូឡាញ្ញាណពុទ្ធចក្រវនារាមក្នុងសហរដ្ឋអាមេរិក និងវត្តថៃលុម្ពិនីក្នុងប្រទេសនេប៉ាល់។ ប្រទេសជិតខាងក្នុងអាស៊ីអាគ្នេយ៍ក៏មិនត្រូវបានមើលរំលងផងដែរ។ សម្តេចបាននិមន្តធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាដើម្បីចូលរួមពិធីបុណ្យព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធនិងមហាសាវ័ករបស់ព្រះអង្គនៅទីក្រុងភ្នំពេញ។ ក្រោយមកព្រះអង្គក៏បាននិមន្តទស្សនកិច្ចទីក្រុងយ៉ាងហ្គុនប្រទេសមីយ៉ាន់មាដើម្បីចូលរួមការប្រជុំលើកទី២នៃការសូធ្យសង្គាយនាព្រះត្រៃបិដកទី៦ (ឆដ្ឋសង្គាយនា)។ ក្រោយមកក្នុងឆ្នាំ១៩៩១ រដ្ឋាភិបាលមីយ៉ាន់មាបានប្រគេនសម្តេចនូវគោរមងារពិសេស “អភិធជមហារដ្ឋគុរុ” ដែលអាចធៀបស្មើនិងគោរមងារព្រះសង្ឃរាជក្នុងប្រទេសនោះ។ ព្រឹត្តិការណ៍នោះបញ្ជាក់ពីជម្រៅនៃទំនាក់ទំនងរវាងប្រជាជាតិទាំងពីរ។

ការខិតខំប្រឹងប្រែងរបស់សម្តេចបានជួយប្រតិស្ថានព្រះពុទ្ធសាសនាថេរវាទឲ្យតាំងនៅរឹងមាំក្នុងប្រទេសជាច្រើន និងបានធ្វើឲ្យព្រះធម៍លូតលាស់ចម្រើនពេញពិភពលោក។ គ្រប់ទីកន្លែងដែលព្រះអង្គបាននិមន្តទៅ ការប្រព្រឹត្តអាកប្បកិរិយាស្រគត់ស្រគំរបស់ព្រះអង្គបានទាក់ទាញឲ្យមានការគោរពស្រលាញ់ និងការចូលចិត្តពីស្រទាប់មហាជន។ វត្តមានក្លិនក្រអូបនៃសីលសំវររបស់ព្រះអង្គបានផ្សព្វផ្សាយយ៉ាងទូលំទូលាយបង្កើតបានជាចំណងផ្លូវចិត្តយ៉ាងរឹងមាំក្នុងចំណោមប្រទេសដែលព្រះអង្គបាននិមន្តទៅ។

"គ្មានអ្វីសប្បាយរីករាយជាងសប្បាយចិត្តនោះទេ សប្បាយចិត្តដែលកើតពីមេត្តា។ ដូច្នេះ ការបណ្តុះពូជមេត្តាគឺមានសារៈសំខាន់និងចាំបាច់ណាស់"។

(ធម្មទានឈ្នះអស់ទានទាំងពួង)

(2nd from right) 1954: His Holiness attending the Sixth Tipitaka Rehearsal in Yangon, Myanmar

សេចក្តីថ្លែងការណ៍ស្តីពីព្រះពុទ្ធសាសនា

"យើងគ្រប់គ្នានៅក្នុងសហគមន៍មួយឬប្រទេសមួយ មានការទទួលខុសត្រូវចំពោះភាពសប្បាយរីករាយនៃបុគ្គលគ្រប់រូប។ ប៉ុន្តែ ក្នុងឋានៈជាមេដឹកនាំបុគ្គលត្រូវតែប្រព្រឹត្តជាគំរូ ដើម្បីបង្កើតនូវស្ថង់ដារកម្រិតខ្ពស់ សម្រាប់អ្នកនៅក្រោមឱវាទ និងអ្នកនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ដូច្នេះ ការទទួលខុសត្រូវរបស់អ្នកដឹកនាំមានទម្ងន់ជាងអ្នកដទៃ។ ក្នុងន័យនេះព្រះពុទ្ធបានសម្តែងបញ្ជាក់ថា អ្នកដឹកនាំនៃក្រុមមួយឬអ្នកដឹកនាំនៃប្រទេសមួយ ចាំបាច់ត្រូវតែតាំងនៅក្នុងធម៌"។

(ព្រះធម៌សម្រាប់ព្រះមហាក្សត្រនិងការអភិវឌ្ឍន៍សង្គម)

នៅថ្ងៃសុក្រទី២១ ខែមេសា ឆ្នាំ១៩៨៩ ព្រះរាជពិធីដ៏ធំមួយត្រូវបានប្រារព្ធឡើងនៅវត្តព្រះកែវមរតក ហើយសម្តេចព្រះញាណសំវរត្រូវបានប្រកាសជាព្រះសង្ឃរាជសាកលមហាសង្ឃបរិនាយកថ្មី ព្រះសង្ឃរាជទី១៩នៃប្រទេសថៃ។

នៅក្នុងប្រទេសថៃ ក្រោមការគ្រប់គ្រងរបស់ព្រះសង្ឃរាជ ព្រះសង្ឃដែលមានគោរម្យងារជាសម្តេចនិងព្រះរាជាគណៈ បដិបត្តិន្ទវត្តនាទីរៀង១ខ្លួន នៅទូទាំងនៃព្រះរាជាណាចក្រថៃ។ មន្ត្រីសង្ឃក្នុងតំណែងទាំងពីរនេះក៏ទទួលបានគោរម្យងារមួយចំនួន។ គោរម្យងារភាគច្រើនឆ្លុះបញ្ចាំងអំពីសភាពផ្លូវចិត្តនៃភិក្ខុអង្គនោះ ជាពិសេសគោរម្យងារដែលបានប្រគេនដល់សម្តេចព្រះសង្ឃរាជ។ គោរម្យងារជាសមណសក្តិពិសេស “សម្តេចព្រះញាណសំវរ ដែលបានប្រគេនចំពោះព្រះសង្ឃរាជក្នុងឆ្នាំ១៩៧២ មានអត្ថន័យថា “ភិក្ខុដែលមានបញ្ញាញាណដ៏ឧត្តុងឧត្តម”។ គោរម្យងារនេះត្រូវបានបង្កើតឡើងក្នុងរជ្ជកាលព្រះបាទរាមាទី២ក្នុងឆ្នាំ១៨១៦។ គោរម្យងារនិងសមណសក្តិជាអធិបតីវិបស្សនាធុរៈត្រូវបានប្រគេនចំពោះសម្តេចព្រះញាណសំវរ (សុកទី១ ក្នុងឆ្នាំ១៨១៦)។ បន្ទាប់ពីសម្តេចដែលបានក្លាយជាព្រះសង្ឃរាជក្នុងឆ្នាំ១៩២០ មិនមានភិក្ខុអង្គណាបានទទួលនូវគោរម្យងារពិសេសនោះឡើយ។ ១៥២ឆ្នាំក្រោយមក សម្តេចបានក្លាយទៅជាភិក្ខុអង្គទី២ដែលត្រូវបានប្រគេននូវគោរម្យងារ “សម្តេចព្រះញាណសំវរ”។ សមត្ថភាពដ៏ធំធេងរបស់ព្រះអង្គក្នុងការបដិបត្តិតួនាទីជាអធិបតីវិបស្សនាធុរៈត្រូវបានមហាជនគោរពសសើរយ៉ាងខ្លាំង។

ជាង់នេះទៅទៀត ព្រះសង្ឃរាជដែលមិនជាប់ខ្សែរាជវង្ស ជាធម្មតាត្រូវបានប្រគេនគោរម្យងារ (សម្តេចព្រះអរិយវង្សគតញ្ញាណ) ។ សម្តេចគឺជាព្រះសង្ឃរាជមិនជាប់ខ្សែរាជវង្សលើកទី១ ដែលប្រើគោរម្យងារពិសេស ”សម្តេចព្រះញាណសំវរ” ជាការទទួលស្គាល់នូវស្នាព្រហស្តផ្នែកសិក្សាធិការយ៉ាងច្រើនរបស់ព្រះអង្គ និងគុណធម៌ផ្នែកខាងការសង្រួមនិងសមាធិ។ សម្តេចគឺជាភិក្ខុគំរូមួយអង្គដែលត្រូវបានទទួលការគោរពពីមនុស្សទាំងឡាយគ្រប់ជាតិពន្ធុ ឋាន: និងសញ្ជាតិ។

សម្តេចមានថេរដីការថា គោលបំណងចម្បងរបស់ព្រះអង្គក្នុងការបង្រៀនព្រះធម៌ដល់ឃុវជននិងសាធារណៈជនគឺ ដើម្បីកសាងសន្តិភាពនិងសេចក្តីសុខសម្រាប់ប្រជាជាតិទាំងមូល។ ព្រះអង្គបង្រៀនមនុស្សគ្រប់គ្នាឱ្យយល់ពីតម្លៃ និងគាំទ្រស្តាប័នព្រះមហាក្សត្រពីព្រោះព្រះអង្គយល់ឃើញថា ប្រជាពល

រដ្ឋថៃចាត់ទុកព្រះមហាក្សត្រជាបេះដូងនៃប្រជាជាតិ។ សម្តេចជឿថា ការរស់រានមានជីវិតនិងសុខមាលភាពប្រទេសជាតិពឹងពាក់លើស្ថាប័នព្រះមហាក្សត្រ។ ប្រទេសបានរួបរួមគ្នានិងរឹងមាំនៅពេលប្រជាពលរដ្ឋទទួលយកនិងគោរពគុណធម៌ព្រះមហាក្សត្រ។

ក្នុងឆ្នាំ១៩៥៦ នៅពេលសម្តេចមានគោរម្យងារជា “ព្រះសោភណគណភរណ៍”ព្រះអង្គត្រូវបានតែងតាំងជាទីប្រឹក្សានិងព្រះរាជគ្រូរបស់ព្រះមហាក្សត្រនៅពេលព្រះមហាក្សត្រសាងផ្នួសជាភិក្ខុនៅវត្តបវរនិវេសវិហារ ក្នុងកំឡុងពេល១៥ថ្ងៃ។

ក្នុងឆ្នាំ១៩៧៨ នៅពេលព្រះអង្គម្ចាស់ព្រះរាជទាយាទ វជិរាឡុងកន បានបួសជាភិក្ខុនិងគង់នៅវត្តបវរនិវេសវិហារ សម្តេចដែលមានគោរម្យងារជាសម្តេចព្រះញាណសំវរត្រូវបានតែងតាំងជាព្រះកម្មវាចាចារ្យដែលមានតួនាទីជាជំនួយការព្រះឧបជ្ឈាយ៍ក្នុងកំឡុងពិធីបំបួសនិងក្រោយមកបានអប់រំព្រះរាជទាយាទនូវវត្តប្រតិបត្តិក្នុងនាមជាភិក្ខុ។សម្តេចគឺជាធម្មាចារ្យចម្បងរបស់ព្រះរាជទាយាទក្នុងកំឡុងរយៈពេលសាងផ្នួស។

សម្តេចបានចាត់ចែងតួនាទីនិងភារៈ កិច្ចរបស់ព្រះអង្គដោយត្រឹមត្រូវឥតខ្ចោះនិងត្រូវបានគោរពកោតក្រែងដោយព្រះមហាក្សត្រនិងព្រះមហាក្សត្រិយានី ដែលព្រះអង្គទាំងទ្វេតែងតែនិមន្តសម្តេចទៅសម្តែងព្រះធម៌នៅគ្រប់ព្រះរាជពិធីបុណ្យសាសនាទាំងក្នុងផ្លូវការនិងក្នុងការចូលថ្វាយព្រះពរជាលក្ខណៈឯកជនដល់ព្រះអង្គទាំងទ្វេ។សមាជិកព្រះរាជវង្សានុវង្សមានការគោរពយ៉ាងខ្លាំងចំពោះសម្តេច ហើយតែងតែយាងមកសួរសុខទុក្ខនិងសាកសួរព្រះធម៌ជាមួយព្រះអង្គ។

មហាករុណានិងការយកព្រះទ័យទុកដាក់របស់សម្តេចគឺគ្របដណ្តប់លើគ្រប់សមាជិកក្នុងសង្គមអោះបីជាព្រះអង្គបានប្រគល់ការងារនិងតំណែងដល់មន្ត្រីសង្ឃនៅពេញព្រះរាជាណាចក្រក៏ព្រះអង្គនៅតែតាមដានបញ្ហាទាំងអស់យ៉ាងជាប់លាប់ព្រោះថាការទទួលខុសត្រូវចុងក្រោយគឺធ្លាក់មកលើព្រះអង្គ។ច្បាប់និងបទបញ្ជាត្តិដែលមិនអំណោយផលដល់សកម្មភាពគណៈសង្ឃត្រូវបានកែប្រែ។

ក្នុងឋានៈជាព្រះសង្ឃរាជនៃគណៈសង្ឃថៃ សម្តេចបានជួបនិងស្វាគមភ្ញៀវអន្តរជាតិជាច្រើន។ ភាពសាមញ្ញរម្យទមរបស់ព្រះអង្គធ្វើឲ្យអ្នកដឹកនាំជាតិជាច្រើនចាប់អារម្មណ៍ដែលបានទទួលស្គាល់ថាជាមេដឹកនាំសាសនាដ៏ធំមួយអង្គនៃពិភពលោក មិនមែនគ្រាន់តែជាប្រមុខដឹកនាំនៃព្រះពុទ្ធសាសនាថៃប៉ុណ្ណោះទេ។ ចរិយាសុភាពរាបសារនិងឱនលំទោនរបស់ព្រះអង្គត្រូវបានគេកោតសរើរយ៉ាងខ្លាំង ដូចគ្នាទៅនិ

ងសមត្ថភាពបញ្ញាញាណរបស់ព្រះអង្គក្នុងការធ្វើសេចក្តីសម្រេចនានា។

ក្នុងឆ្នាំ១៩៦៧ សម្តេចដាឡៃឡាម៉ាទី១៤ ដែលជាប្រមុខដឹកនាំពុទ្ធសាសនាទីបបានបំពេញទស្សនកិច្ចមកកាន់ប្រទេសថៃជាលើកដំបូង។ ព្រះអង្គបានយាងទៅជួបសម្តេចព្រះសង្ឃរាជនៅវត្តបវរនិវេសនិងបានទទួលការពិគ្រោះយោបល់ស្តីអំពីការសមាធិបែបព្រះពុទ្ធសាសនាថេរវាទ។ នៅពេលសម្តេចដាឡៃឡាម៉ាបានយាងបំពេញទស្សនកិច្ចនៅប្រទេសថៃ និងបានគង់នៅវត្តបវរនិវេសក្នុងឆ្នាំ១៩៩៣ ព្រះអង្គបានថ្លែងទៅកាន់សម្តេចព្រះសង្ឃរាជថៃដែលពោលថា “បងប្រុសរបស់ខ្ញុំ” ក្នុងការទទួលស្គាល់នូវចំណងនៃការស្រលាញ់គ្នាជាបងប្អូននិងការកោតក្រែងគ្នាទៅវិញទៅមកររាងប្រមុខដឹកនាំពុទ្ធសាសនាទាំងពីរអង្គ។ អស់រយៈពេលជាង៨០ឆ្នាំ ចាប់តាំងតែពីសម្តេចបានចូលមកកាន់ផ្លូវព្រះធម៌ជាសាមណេរ ការគោរពបូជាចំពោះព្រះធម៌របស់ព្រះអង្គនិងការធ្វើប្រយោជន៍ជាសាកលដល់មនុស្សជាតិមិនដែលថមថយឡើយ។ ក្នុងឋានៈជាប្រមុខគណៈសង្ឃថៃ ការប្រព្រឹត្តព្រហ្មចរិយធម៌និងការបំពេញការងាររបស់ព្រះអង្គកាន់តែខ្លាំងឡើងៗ ហើយត្រូវបានគេគោរពកាន់តែច្រើន និងក្លាយទៅជាការជំរុញលើកទឹកចិត្តដល់ដែលបានប្រាស្រ័យជាមួយព្រះអង្គ។

Buddha and Arahat Relics enshrined at Preah Vihear Preah Keo Morakot in



"ការបើញព្រះធម៌គឺជាការបើញនូវសភាវៈដូវចិត្តខ្លួនឯង អាំឯណាំឯអក្រក់។ កំណត់ដឹងថាតាមសភាពពិត គឺដឹងនូវភាពពិតនៃចិត្តរបស់ខ្លួន"។

(អ្វីដែលព្រះពុទ្ធបានបង្រៀន)

ជោគិតាពរបស់សម្តេច

"ពុទ្ធសាសនិក 'មនុស្សប្រកបដោយបញ្ញា' សំដៅដល់មនុស្សដែលមានការយល់ដឹងច្បាស់លាស់ និងមានហេតុផល យល់ដឹងអំពីមូលហេតុនិងផលវិបាកហូរចឹញជាបន្តបន្ទាប់។ បុគ្គលនោះគឺជាមនុស្សដែលយល់ដឹងអំពីមូលហេតុនៃការធ្វើល្អឬអាក្រក់ និងយល់ដឹងអំពីផលវិបាកនៃអំពើល្អនិងអាក្រក់។ លើសពីនេះទៅទៀត បុគ្គលនោះដឹងថា ហេតុបច្ច័យល្អតែមួយគត់ដែលនាំមកនូវផលវិបាកល្អ និងហេតុបច្ច័យអាក្រក់នាំមកនូវផលវិបាកអាក្រក់។ មិនមានហេតុបច្ច័យល្អអាចនាំឲ្យកើតនូវផលវិបាកអាក្រក់ឡើយ ហើយក៏មិនមានហេតុបច្ច័យអាក្រក់អាចនាំឲ្យកើតនូវផលវិបាកល្អដែរ។ បុគ្គលដែលយល់ដឹងអំពីហេតុបច្ច័យនិងផលវិបាកពិតប្រាកដ ដូចព្រះពុទ្ធបានបង្រៀន ត្រូវចាត់ទុកជា "បុគ្គលឆ្លាត" តាមអត្ថន័យក្នុងព្រះពុទ្ធសាសនា។ បុគ្គលទាំងនោះនឹងមិនចាកអំពើអាក្រក់ទាំងឡាយ។ ពួកគេនឹងប្រព្រឹត្តតែអំពើល្អប្រកបដោយភាពក្លាហាន និងដោយគ្មានការស្ទាក់ស្ទើរដើម្បីប្រយោជន៍ខ្លួនឯងនិងអ្នកដទៃ។ ពួកគេធ្វើបែបនេះ ទោះជាត្រូវចំណាយកម្លាំងកាយចិត្តយ៉ាងណា ទោះជាត្រូវចំណាយថវិកាឬទ្រព្យសម្បត្តិប៉ុណ្ណា ក៏ដោយ"។

សោភណកថា៖ ធម្មទេសនាក្នុងរាជាសចរមីនព្រះជន្មវស្សាព្រះមហា-ក្សត្រិយានី នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩១ នៅមហា

ប្រាសាទ អមរិន្ទ្រវិនិច្ឆ័យ ក្នុងព្រះបរមរាជវាំង

“បញ្ញាគឺជាពន្លឺនៃពិភពលោក បណ្ឌិតទាំងឡាយគួរតែជ្រមុជខ្លួនក្នុងបញ្ញា” ។ ភាសិតនេះដកស្រង់ពីគម្ពីរភាសាបាលី ដែលសម្តេចព្រះសង្ឃរាជបានបកប្រែ ឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីអ្វីដែលព្រះអង្គបានអភិវឌ្ឍន្ធរូបបញ្ញាញាណរបស់ព្រះអង្គ រហូតដល់វាមានពន្លឺយ៉ាងចិញ្ចាចចិញ្ចែង។ ភាពវីរាយពេញចិត្តរបស់ព្រះអង្គក្នុងការរៀនសូត្របាននាំឲ្យមានការអភិវឌ្ឍទាំងជំនាញក្នុងការយល់ដឹងនៃគម្ពីរ និងស្មារតីផ្លូវចិត្តរបស់ព្រះអង្គ។

សម្តេចព្រះសង្ឃរាជគឺជាអ្នកប្រាជ្ញមួយអង្គមានទស្សនវិស័យដ៏ឆ្ងាយសព្វព្រះទ័យនឹងការស្រាវជ្រាវនិងវិភាគគ្រប់ផ្នែកទាំងអស់នៃពុទ្ធសាសនា និងបានដាក់ព្រះកាយធ្វើការសាកល្បងនូវរបកគំហើញថ្មី។ ព្រះអង្គគឺជាបណ្ឌិតពិតប្រាកដ ជាអរិយសង្ឃមួយអង្គ ដែលមានចំណេះដឹងជ្រៅជ្រះ និងគោរពវិន័យយ៉ាងម៉ឺងម៉ាត់។

បញ្ញាញាណគួបផ្សំនឹងបទពិសោធន៍ខាងកិច្ចការពុទ្ធសាសនាយ៉ាងទូលំទូលាយរបស់ព្រះអង្គបានធ្វើឲ្យកិច្ចការសាធារណរបស់ព្រះអង្គត្រូវបានគេវាយតម្លៃខ្ពស់និងចាត់ទុកជាការងារសាសនាដ៏សំខាន់ផងដែរ។ (ការងារទាំងនេះរួមមាន សៀវភៅ អត្ថបទ **ការសាងសង់ឫជនីយដ្ឋានសាសនា** ការជួសជុលស្តុបតៀកម្មពុទ្ធសាសនាបុរាណ និងការបង្កើតនូវរូបចម្លាក់ព្រះពុទ្ធនិងវត្ថុសំក្តិសិទ្ធិ)។

ស្នាព្រះហស្តសំខាន់ៗរបស់ព្រះអង្គអាចបែងចែកជាប្រភេទដូចខាងក្រោម៖

ប្រព័ន្ធផ្សព្វផ្សាយ

ឆ្លើយតបទៅនឹងការស្នើសុំរបស់ ព្រះអង្គម្ចាស់ក្សត្រិយ៍ សម្តេចព្រះវរមាតា ស្រីនគរិន្ទ្រា សម្តេចព្រះសង្ឃរាជបានចាប់ផ្តើមធ្វើការផ្សព្វផ្សាយតាមវិទ្យុនៅពេលព្រឹកថ្ងៃអាទិត្យ អំពី “ការគ្រប់គ្រងចិត្ត” នៅស្ថានីយ៍វិទ្យុអម្ពរស្ថាន (អ.ស.) នៅក្នុងព្រះរាជវាំងតុសិត និងបានបន្តកម្មវិធីនេះអស់រយៈពេលជាច្រើនឆ្នាំ។ គោលបំណងនៃការផ្សព្វ ផ្សាយគឺដើម្បីបង្រៀនអ្នកស្តាប់អំពីវិធីចម្រើនសតិនិងប្រើប្រាស់សតិសម្រាប់ជីវិតប្រចាំថ្ងៃ។ ព្រះអង្គ ថែមទាំងបានសរសេរអត្ថបទអំពីព្រះពុទ្ធសាសនាចុះផ្សាយលើទស្សនាវដ្តីស្ត្រីឈ្មោះថា “ស្រីសប្តាហ៍” និងទស្សនាវដ្តីពុទ្ធសាសនា ឈ្មោះ “ធម្មចក្ខុ” បោះពុម្ពផ្សាយដោយ មូលនិធិមហាមកុដរាជវិទ្យាល័យ ។

សៀវភៅ

សម្តេចព្រះសង្ឃរាជសព្វព្រះទ័យលើភាសាបរទេស ដូចជា សំស្ក្រឹត អង់គ្លេស បារាំង អាល់ឡឺម៉ង់ និងចិន។ ប៉ុន្តែ ភាសាបរទេសតែមួយគត់ដែលព្រះអង្គអាចធ្វើការសន្ទនាបានយ៉ាងល្អគឺអង់គ្លេស ហើយព្រះអង្គមានជំនាញក្នុងការអាន សរសេរ និងនិយាយភាសានេះបានយ៉ាងល្អ។ ជំ







នាញនេះគួបផ្សំនឹងចំណង់ចំណូលចិត្តឥតនឿយ ណាយក្នុងការស្រាវជ្រាវ ធ្វើឲ្យសៀវភៅរបស់ព្រះអង្គមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងភាពជ្រាលជ្រៅ។ ព្រះអង្គមានសមត្ថភាពអាចទទួលយកនូវចំណេះដឹងថ្មីៗនិងប្រើប្រាស់ចំណេះដឹងទាំងនោះដើម្បីពន្យល់ព្រះធម៌យ៉ាងមានប្រសិទ្ធភាពដែលធ្វើឲ្យសៀវភៅរបស់ព្រះអង្គងាយយល់ដល់មនុស្សគ្រប់វ័យ និងជំរុញឲ្យមនុស្សជាច្រើនចាប់អារម្មណ៍សិក្សាព្រះធម៌។ សៀវភៅមួយចំនួនរបស់ព្រះអង្គគឺ៖

សោឡសបញ្ហា

សៀវភៅនេះនិយាយអំពីសំនួរព្រះធម៌ល្អិតសុខុមទាំង១ ៦ អមដោយការពន្យល់ផងដែរ។ វាផ្តុះបញ្ចាំងអំពីការវិភាគយ៉ាងច្បាស់លាស់នៃធម្មបរិយាយយ៉ាងជ្រាលជ្រៅ ដែលបង្ហាញឲ្យឃើញនូវសមត្ថភាពរបស់ព្រះអង្គទាំងជំនាញផ្នែកគម្ពីរក្បួនច្បាប់និងភាពប៉ិនប្រសប់ខាងផ្លូវចិត្ត និងវិធីដែលព្រះអង្គអាចប្រើប្រាស់ឥន្ទ្រីយ៍ទាំងពីរក្នុងពេលជាមួយគ្នាយ៉ាងស្ទាត់ជំនាញ។

ទសបារមី ទសពិធរាជធម៌

សម្តេចព្រះសង្ឃរាជបានយល់អំពីទំនាក់ទំនងគ្នារវាងព្រះធម៌ទាំងពីរយ៉ាងនេះ។ ទសបារមី គឺជាគុណធម៌១ ០ យ៉ាង ដែលដឹកនាំទៅរកការសម្រេចចុងក្រោយ (វិមុត្តិ) ឬការត្រាស់ដឹង។ ទសពិធរាជធម៌ គឺជាគុណធម៌លោកិយ១ ០ យ៉ាង ដែលមានគោលបំណងឲ្យមនុស្សសម្រេចបាននូវសុភមង្គល។ ធម៌ទាំងពីរនេះមានមាតិកាប្រហាក់ប្រហែលគ្នានិងផ្តល់ផលចម្រើនក្នុងការសន្សំបុណ្យ។

ចំណុចដែលគួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងសៀវភៅនេះ គឺវិធីសិក្សាបែបប្រៀបធៀបនិងសម្របសម្រួល ដែលដឹកនាំអ្នកអានឱ្យទទួលបាននូវទស្សនៈយល់ឃើញមួយផ្សេងទៀត និងទិដ្ឋភាពកាន់តែទូលាយនៃពុទ្ធសាសនសិក្សា។

៤៥ វស្សារបស់ព្រះពុទ្ធ

សៀវភៅនេះរៀបរាប់អំពី៤៥ឆ្នាំនៃជីវិតរបស់ព្រះពុទ្ធ ចាប់តាំងពីការត្រាស់ដឹងរហូតដល់បរិនិព្វាន (សុគត) និងការរួចស្រឡះចាកវដ្ដៈនៃការកើតចាស់ឈឺស្លាប់ ក្បែរក្រុងកុសិនារា។ សម្តេចព្រះសង្ឃរាជបានប្រមូលចងក្រងនូវព្រឹត្តិការណ៍និងប្រវត្តិដោយដកស្រង់ចេញពីព្រះត្រៃបដក អត្ថកថា គម្ពីរដីកា និងសៀវភៅផ្សេងៗទៀត រួមទាំងគម្ពីរមហាយាន ហើយនិទានឡើងវិញនូវពុទ្ធប្បវត្តិជាបែបនិទានកថាយ៉ាងទាក់ទាញ។ នេះគឺជាសៀវភៅមួយផ្សេងទៀត ដែលបង្ហាញពីភាពល្អិតសុខុមជ្រាលជ្រៅរបស់ព្រះអង្គក្នុងការបង្រៀនព្រះធម៌។

មានស្នាដៃស្រាវជ្រាវផ្សេងទៀត ដែលព្រះអង្គបានសរសេរ រួមមានសៀវភៅវេយ្យាករណ៍ភាសាបាលីភាគមួយនិងភាគពីរ សម្រាប់សិស្សផ្នែកភាសាបាលី។ ព្រះអង្គថែមទាំងបានផ្តួចផ្តើមការចងក្រងនិងបោះពុម្ពផ្សាយនូវវចនានុក្រមបាលី ថៃ អង់គ្លេស និងសំស្ក្រឹត ក្នុងព្រះនាមព្រះអង្គម្ចាស់កិត្តិយសការរលក្សណៈ ទៀតផង។

ការបកប្រែផ្សេងទៀតស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះអង្គ រួមមានសៀវភៅតម្រាំងពុទ្ធសាសនាជាច្រើន ដែលត្រូវបានបកប្រែទៅជាភាសាអង់គ្លេស ដូចជា នវកោវាទ វិន័យមុខ ពុទ្ធប្បវត្តិ ឧបសម្បទាវិធី ភិក្ខុបាតិមោក្ខ និង សៀវភៅសូធ្យព្រះបរិត្ត។ ធម្មទេសនារបស់ព្រះអង្គត្រូវបានបោះពុម្ពផ្សាយជាច្រើន។ធម្មទេសនាដែលបានបោះពុម្ពរួចហើយរួមមានមង្គលវិសេសកថា បញ្ចគុណ ទសពលញ្ញាណ មង្គលទេសនា និងសង្ឃគុណ។

ការកសាងនិងការជួសជុល

ការកសាងនិងការជួសជុលសំណង់ពុទ្ធសាសនាជាច្រើនត្រូវបានធ្វើឡើងដើម្បីការបិតថែរនៃកេរ្តិ៍មរតកពុទ្ធសាសនា និងសំរាប់មនុស្សម្នាសម្តែងនូវមនោសំញ្ចេតនាគោរពដោយសទ្ធាជ្រះថ្លា និងដឹងគុណចំពោះ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។ គម្រោងកសាងនិងជួសជុលជិត១០០ ត្រូវបាន

ផ្តួចផ្តើមឡើងដោយសម្តេចព្រះសង្ឃរាជ ហើយគម្រោងសំខាន់ៗមួយចំនួនមានរាយនាមដូចខាងក្រោម៖

ក. ការកសាងនិងជួសជុលនៅក្នុងស្រុក

ដើម្បីតបស្នងសងគុណប្រកបដោយការដឹងគុណចំពោះ គ្រូឧបជ្ឈាយ៍ គ្រូ-

បង្រៀន និងបុព្វការីជនផ្សេងៗទៀតរបស់ព្រះអង្គ សម្តេចព្រះសង្ឃរាជបានកសាងឧទ្ទិសគម្រោងមួយដល់អ្នកមានគុណមួយរូបៗ ដែលបានបង្ហាញផ្លូវឆ្ពោះទៅរកវិមុត្តិ: ភ.ប.រ.។ សាលសហសិក្សានៅវត្តទេវសង្ឃារាម (វត្តនឿ) ក្នុងការដឹងគុណចំពោះគ្រូឧបជ្ឈាយ៍និងគ្រូបាធ្យាយដំបូងនៃជីវិតផ្នួសរបស់ព្រះអង្គ គឺ: លោកឪ ឪ។ អាគាររាវិទេវនន្ទា ក្នុងការដឹងគុណចំពោះសាលាវត្ត ទេវសង្ឃារាម ជាកន្លែងដែលព្រះអង្គបានរៀនបឋមសិក្សាកាលនៅកុមារ។

អាគារដែលមានក្បួរកបាច់រចនាដ៏ស្អាតមួយ គឺវត្តញាណសំវរារាម នៅក្នុងខេត្ត ជលបុរី ត្រូវបានកសាងឧទ្ទិសចំពោះ ព្រះបាទសម្តេចរាមាទី៩ ដែលជាព្រះមហាក្សត្របច្ចុប្បន្ន និងចំពោះបុព្វការីរាជវង្សានុវង្សទាំងអស់របស់ព្រះមហាក្សត្រ។ ដើម្បីចូលរួមអភិរក្សភ្នំនិងបរិស្ថាន សម្តេចព្រះសង្ឃរាជក៏បានផ្តួចផ្តើមឆ្លាក់រូបចម្លាក់លៀនស្រាលនៃព្រះពុទ្ធ ដាប់ចេញពីទំរាលថ្មភ្នំមានព្រះភ័ក្ត្របែរសំយុងចុះក្រោម ដែលត្រូវគេបានស្គាល់ជា ភ្នំដីចន្ទ្ទ។ ចម្លាក់ដ៏គួរអោយចាប់អារម្មណ៍នេះគឺត្រូវបានគូយ៉ាងប៊ិនប្រសប់ដោយឡាស៊ែរ និងមានការស្រាបមាសផង។ ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធត្រូវបានប្រតិស្ថាននៅក្នុងរូបចម្លាក់ព្រះពុទ្ធផងដែរ។ពិធីសម្ពោធឆ្លងត្រូវបានព្រះមហាក្សត្រ យាងចូលរួមជាអធិបតី។

ព្រះវិហារស្រីនគរិន្ទ្រាមហាសន្តិគីរី ដែលមានពណ៌សនិងពណ៌ប្រផេះយ៉ាងស្រស់ស្អាត នៅវត្តសន្តិគិរីញាណសំវរារាម ដងម៉ែសាឡុង ខេត្តឈៀងម៉ៃ ត្រូវបានសាងសង់ឡើងក្នុងព្រះកិត្តិនាមរបស់សម្តេចព្រះវររាជជននី។ ប្រាង្គព្រះវិហារមានពណ៌មាសយ៉ាងស្រស់ស្អាតនិងបញ្ចេញញ្រពន្លឺភ្លឺតៗនៅលើកំពូលភ្នំ។ មានការកសាងនិងជួសជុលនូវវត្តមួយចំនួនផ្សេងទៀតទាំងនៅតំបន់ជិត និងដាច់ស្រយាល៖ វត្តរាជឧដាភិសេក និងវត្តពុទ្ធវិមុត្តិ នៅខេត្តកញ្ចនបុរី,វត្តវ៉ាងភូសៃនៅខេត្តពេជ្របុរី,និងវត្តឡានណាញាណសំវរារាម នៅខេត្តឈៀងម៉ៃ។

ខ. ការកសាងនិងការជួសជុលនៅក្រៅប្រទេស

ដោយមានសុភវិនិច្ឆ័យដ៏ឆ្លាយ សម្តេចព្រះសង្ឃរាជកត់សម្គាល់អំពីសារៈសំខាន់នៃការងារធម្មទូត (អ្នកផ្សព្វផ្សាយសាសនា) ដោយការជួយពុទ្ធសាសនាថេរវាទក្នុងប្រទេសផ្សេងៗទៀត ហើយនៅពេលជាមួយគ្នានោះ ក៏ចូលរួមចំណែកពង្រឹងទំនាក់ទំនងមិត្តភាពជាមួយសហគមន៍អន្តរជាតិ។ កិច្ចខិតខំប្រឹងប្រែងរបស់ព្រះអង្គអស់រយៈពេលជាច្រើនឆ្នាំ ត្រូវបានចេញជាផ្លែផ្កានៅលើទ្វីបជាច្រើននៃពិភពលោក។

សព្វថ្ងៃ ក្រុមនៃពុទ្ធសាសនាថេរវាទជាច្រើនជុំវិញពិភពលោកបានស្នើសុំសម្តេចធ្វើជាព្រះប្រធាននៃគណៈកម្មការគ្រប់គ្រង ក៏ដូចជាព្រះប្រធាននៃគណៈកម្មការទ្រទ្រង់ ។ នេះគឺដើម្បីសាងសង់វត្ត និងព្រះវិហារ (ឧបោសថាគារ) របស់ពួកគេ ។ ឧទាហរណ៍ វត្តពុទ្ធរង្សី នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ដែលជាវត្តពុទ្ធសាសនាថេរវាទដំបូងនៅលើទ្វីបនេះ, វត្តហ្សាការតាធម្មចក្កជ័យ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី, វត្តការូឡាញ្ញាណពុទ្ធចក្រវត្តារាម នៅសហរដ្ឋអាមេរិក,ព្រះវិហារ(ឧបោសថាគារ)នៃវត្តនគរមណ្ឌបស្រីកិត្តិវិហារ នៅកិត្តិបុរ, និងវត្តថៃលុម្ពិនី នៅលុម្ពិនី ប្រទេសនេប៉ាល់។

Uposatha Hall of Wat Srikiti Vihara in Kathmandu, Nepal

Uposatha Hall of Wat Thai Lumbini in Lumbini, Nepal.



គ. ការកសាងនិងជួសជុលនៅក្នុងវត្តបវរនិវេសវិហារ

ក្នុងឋានៈជាព្រះចៅអធិការនៃវត្តបវរនិវេសវិហារសម្តេចព្រះសង្ឃរាជបានគ្រប់គ្រងជិតដិតនូវការជួសជុលឡើងវិញនៃទីអារាមទាំងមូលរួមមានរចនាសម្ព័ន្ធសំខាន់ៗដូចខាងក្រោម៖

- ព្រះវិហារ (ឧបោសថាគារ): សម្តេចបានជុសជុលឡើងវិញដោយបានក្រាលថ្មកែវមកពីប្រទេសអ៊ីតាលី ក្នុងគោលបំណងរក្សានូវស្ថាបត្យកម្មដើម និងសិល្បៈកម្មបុរាណរបស់វា ដែលជាគំរូតែមួយគត់នៃរចនាបថសិល្បៈបែបនោះ។

- មហាចេតិយរចនាបថបៀបស្រីលង្កា: សម្តេចបានតុបតែងព្រះចេតិយដោយឥដ្ឋការូឡាបូរាណរូបតូចៗពណ៌មាសរបស់អ៊ីតាលី ដែលធ្វើឲ្យព្រះចេតិយមានពន្លឺចាំងភ្លឺកៗយ៉ាងស្រស់ស្អាតនៅពេលមានពន្លឺព្រះអាទិត្យ។

- អាគារសារមន្ទីរ ភ.ប.រ. សារមន្ទីរវត្តបវរនិវេសវិហារត្រូវបានកសាងឡើងដើម្បីតាំងបង្ហាញបុរាណវត្ថុរបស់វត្ត។

- អាគារធម្មនិវេស ស.វ. ត្រូវបានកសាងឡើង ដើម្បីឧទ្ទិសថ្វាយសម្តេចព្រះវររាជជននី។

-អាគារ កវិបណ្ណាល័យ ត្រូវបានកសាងឡើងដើម្បីជាការិយាល័យព្រឹទ្ធបុរស និងបណ្ណាល័យនៃពុទ្ធិកមហាមកុដរាជាវិទ្យាល័យ ។

គម្រោងទាំងអស់ដែលបានរៀបរាប់ខាងលើនេះឆ្លុះបញ្ចាំងមិនត្រឹមតែចក្ខុវិស័យការដឹងគុណ និងថាមពលរបស់សម្តេច ប៉ុន្តែបង្ហាញអំពីបញ្ញាញាណនិងមេត្តាករុណា របស់ព្រះអង្គចំពោះប្រជាជនថៃនឹងដើម្បីសុខុមាលភាពនិងសុភមង្គលនៃពិភពលោក។

"បុគ្គលអាចគិតថាខ្លួនកំពុងធ្វើនូវអ្វីមួយល្អ ប៉ុន្តែប្រសិនចិត្តរបស់គេរសាប់រសល់ គាត់នឹងមិនអាចមានសន្តិភាពឡើយ។ ប្រសិនបើជួបស្ថានភាពមែនទែន បុគ្គលនោះប្រាប់ថា តាមពិតគេគ្រាន់តែព្យាយាមបង្ហាញថាកំពុងធ្វើអំពើល្អ។ (ចំរ្លឺផ្លូវចិត្ត)

"លទ្ធភាពនៃកុសល និងអកុសលកើតឡើងបានគ្រប់ពេលវេលាទាំងអស់ ប៉ុន្តែវាមិនកើតឡើងក្នុងពេលជាមួយគ្នានោះឡើយ។ យើងត្រូវតែធ្វើមួយនេះ ឬមួយនោះ។ យើងត្រូវតែជ្រើសរើសយោងល្អ និងអាក្រក់។ ចូរកុំស្អាក់ស្ទើធ្វើនូវសេចក្តីល្អ។ ចូរកុំប៉ុនប៉ងធ្វើនូវសេចក្តីអាក្រក់, ពីព្រោះថា ប្រសិនបើអ្នកឆ្លាក់ចូលក្នុងអំណាចនៃសេចក្តីអាក្រក់ វានឹងរារាំងនូវឱកាសរបស់អ្នកក្នុងការធ្វើនូវសេចក្តីល្អ"។

(មួយជីវិតមានប្រយោជន៍ពិត)

ជីវិតព្រហ្មចរិយៈរបស់សម្តេច

"ព្រះធម៌គឺជាគ្រឿងអលង្ការដែលលម្អចិត្តរបស់បុគ្គល, ចូរអប់រំ ហាត់ពត់ចិត្ត រហូតទាល់តែចិត្តត្រូវបានអភិវឌ្ឍបណ្តុះផ្សាំបានយ៉ាងល្អ, ធ្វើឲ្យចិត្តរុងរឿង, និងធ្វើមនុស្សឲ្យក្លាយជាមនុស្សពិតប្រាកដ និងធ្វើឲ្យមនុស្សក្លាយជាមនុស្សដែលគេគោរព សរសើរ, ជាមនុស្សមានការសិក្សាអប់រំ, និងជាមនុស្សដែលពោរពេញដោយសេចក្តីសុខស្ងប់។ ប្រសិនបើយើងប្រៀបធៀបទៅនឹងរង្វាស់ពិភពលោកនោះ, ព្រះធម៌គឺប្រៀបបីដូចជាការបណ្តុះផ្សាំ ចិញ្ចឹម និងការទ្រទ្រង់នូវជីវិត ដែលប្រៀបបីដូចជាគ្រឿងអលង្ការមាស ពេជ្រ ដែលលម្អនូវរាងកាយខាងក្រៅរបស់យើងយ៉ាងអួងអែរ"។

(គោលធម៌គ្រឹះពុទ្ធសាសនា)

"ប្រសិនបើអ្នកប្រាថ្នាគោរពចំពោះព្រះសង្ឃល្អ, មានគុណធម៌, អ្នកមិនចាំបាច់ធ្វើដំណើរទៅកាន់ទីឆ្ងាយរហូតទៅដល់ឈៀងម៉ៃនោះឡើយ។ អ្នកមានព្រះសង្ឃល្អ, មានគុណធម៌មួយអង្គរួចទៅហើយនៅក្នុងទីក្រុងបាងកក។ ធ្វើដំណើរទៅថ្វាយបង្គំសម្តេចព្រះញាណសំវរៈទៅ" ។ បើនិយាយដល់ឱឿងនេះ គឺយើងនឹកទៅដល់ លោកឱម៉ែន ដែលបានពោលទៅកាន់សាវ័ករបស់លោក ដែលបានធ្វើដំណើរពីរាជធានីនៃប្រទេសថៃ ទៅកាន់វត្តដយម៉ែបាង ខេត្តឈៀងម៉ៃ, ដែលជាកន្លែងលោកឱកំពុងគង់នៅ។

វាចាដែលបានថ្លែងខាងលើគឺជាការបញ្ជាក់ម្តងទៀតអំពីព្រះសង្ឃដ៏ល្បីល្បាញអង្គនោះ, លោកឱម៉ែន ដែលគេបានស្គាល់ស្មើរគ្រប់គ្នាថា សុបដិបន្នោ, ដែ

His Holiness was with deaf students.

លជីវិតព្រហ្មចរិយៈរបស់លោកពោរពេញដោយភាពបរិសុទ្ធិ និងបានក្លាយជាប្រទីបសម្រាប់ប្រជាពលរដ្ឋថៃគ្រប់រូបនៅក្នុងរាជធានីថៃនាសម័យទំនើបនេះ។

សម្តេចតែងតែគោរព និងបដិបត្តិជីវិតតាមព្រះធម៌ជានិច្ច, ដែលធ្វើឲ្យមនុស្សរាល់គ្នាស្គាល់ព្រះអង្គ មានអារម្មណ៍ថាព្រះធម៌តាមលម្ហព្រះអង្គ។ គោរម្យងារ ព្រះរាជាគណៈ: “ព្រះសោភណគុណាភរណ៍” មានន័យថា “ប៉ៀបដូចជាត្បូង ឬ ស្បង់ចីវរដែលលម្អសហគមន៍ខ្លួន”, ហេតុដូច្នេះហើយ គោរម្យងារនេះត្រូវបានប្រគេនដល់ព្រះអង្គ ក្នុងឆ្នាំ១៩៤៧។ គោរម្យងារបស់ព្រះអង្គបន្ទាប់មកទៀតគឺ: ព្រះធម្មវរាភរណ៍ ដែលត្រូវបានប្រគេនដល់ព្រះអង្គ ក្នុងឆ្នាំ១៩៥៦, ។

ប្រជាពលរដ្ឋដែលបានឃើញសម្តេច ទោះបីពីទីជិតឬឆ្ងាយ ហើយរាល់អ្នកទាំងឡាយណាដែលសម្តេចបានមានសង្ឃដីកាសន្ទនាជាមួយនោះ តែងតែមានការពេញចិត្តនឹងកាយវិការរម្យទម និងមានសេចក្តីសប្បាយរីករាយនឹងសេចក្តីស្ងប់របស់ សម្តេច។ ធម្មជាតិនៃមេត្តាករុណាដែលបានផុសចេញពីក្នុងហឫទ័យសម្តេចបានជំរុញនូវសទ្ធា ការជឿជាក់របស់ប្រជាពុទ្ធបរិស័ទ ព្រមទាំងព្រះសង្ឃទាំងឡាយផងដែរ។ វត្តមានរបស់សម្តេចបានបណ្តុះនូវក្តីសង្ឃឹមនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ដែលអាចទទួលបាននូវសេរីភាព និងបានសម្រាលនូវសេក្តីទុក្ខ ប្រសិនបើពួកគេដើរតាមមាគ៌ារបស់ព្រះសាសនា, រស់នៅអាស្រ័យនឹងព្រះធម៌។

ជីវិតប្រចាំថ្ងៃ

ជារៀងរាល់ថ្ងៃនៅប្រហែលជាម៉ោង ៤ព្រឹក សម្តេចបានតើនឡើង,សូធ្យធម៌នមស្សការហើយធ្វើសមាធិមុនពេលចេញទៅទ្រង់បិណ្ឌបាត្រ។ នៅម៉ោង ៩ ព្រឹក សម្តេចឆាន់ចង្ហាន់ផ្ទាល់ពីក្នុងបាត្រ ដោយមួយថ្ងៃសម្តេចឆាន់តែមួយពេលប៉ុណ្ណោះ។ សម្តេចទទួលជួបសំណេះសំណាលជាមួយនឹងញាតិញោមមួយម៉ោងនៅពេលព្រឹក ហើយនឹងមួយម៉ោងនៅពេលរសៀល បើមិនដូច្នោះទេ ទ្រង់អានសៀវភៅ ឬស្រាវជ្រាវ។

សម្តេចទទួលការនិមន្តទាំងអស់តាមតែអាចទទួលបានពីប្រជាពលរដ្ឋគ្រប់មជ្ឈ- ដ្ឋាន, វាអាចជាការបើកសម្ពោធហាងតូចមួយ ឬពិធីធំឲ្យតែប្រជាពលរដ្ឋរៀបចំវា ព្រះអង្គសព្វព្រះទ័យទទួលទទួលការនិមន្តទាំងអស់។ នៅពេលឧបដ្ឋាក:ផ្ទាល់របស់ព្រះអង្គមានការព្រួយបារម្ភចំពោះសម្តេច ព្រោះព្រះអង្គប្រឹងប្រែងធ្វើការខ្លាំងពេក សម្តេចបានពន្យល់ពួកគេដោយសុភាពថា “អាត្មាជាព្រះសង្ឃរបស់ប្រជាជន”។

នៅពេលល្ងាច ខណៈកំដៅថ្ងៃបានចុះថយទៅ សម្តេចតែងនិមន្តមើលជុំវិញវត្តអារាមទុកជាការហាត់ប្រាណ បន្ទាប់មកក៏បានធ្វើឯកសារនិងការសិក្សាស្រាវជ្រាវបន្ថែម និងធ្វើសមាធិរហូតដល់ពេលចូលសឹង។ សម្តេចទ្រង់សឹងមិនលើសពី ៣ ទៅ ៤ ម៉ោងប៉ុណ្ណោះ ក្នុងមួយរាត្រី ។

ការរស់នៅប្រកបដោយសតិ

សេចក្តីស្ងប់និងការគោរពព្រះវិន័យត្រៃសិក្ខាដ៏តឹងរឹង គឺជាផ្នែកមួយនៃអត្តចរិតរបស់សម្តេច។ ព្រះអង្គបានសិក្សានូវសិក្ខាបទរបស់អ្នកបួសយ៉ាងប្រុងប្រយ័ត្ន ហើយតែងតែមានសតិរឭកជាប់ជានិច្ច មិនប្រព្រឹត្តបំពានឡើយ។ សម្តេចទ្រង់ប្រើគ្រប់ខណៈទាំងអស់ដែលអាចធ្វើបានដើម្បីចម្រើនសមាធិ។ ជារឿយៗ ប្រជាពុទ្ធបរិស័ទតែងតែឃើញព្រះអង្គទ្រង់គង់មានព្រះកាយត្រង់ បិទព្រះនេត្រទាំងគូ ប្រកបដោយសេចក្តីសុខស្ងប់។

បន្ទាប់មកព្រះអង្គទ្រង់ចាប់ផ្តើមបន្តការសិក្សារបស់ព្រះអង្គដោយស្ងាត់ស្ងៀមតាមកាលវិភាគដែលបានកំណត់។

កតញ្ញូតាធម៌

សម្តេចតែងតែចងចាំ និងមានកតញ្ញូតាធម៌ចំពោះអ្នកដែលមានចិត្តសប្បុរសចំពោះព្រះអង្គនៅក្នុងវ័យកុមារ ហើយតែងស្វែងរកឱកាសដើម្បីបានតបស្នងគុណូបការៈចំពោះអ្នកទាំងអស់វិញ។ ដូច្នេះ កតញ្ញូតាធម៌ គឺជាអាកប្បកិរិយាដ៏លេញឆ្ពោះមួយរបស់សម្តេច ជាផ្នែកមួយដ៏សំខាន់នៃជីវិតព្រះអង្គ ដែលបញ្ជាក់អំពីបុគ្គលិកលក្ខណៈនៃជីវិតព្រហ្មចរិយៈរបស់ព្រះអង្គ។

ជារៀងរាល់ឆ្នាំ សម្តេចតែងតែប្រារព្ធពិធីបុណ្យ ដើម្បីឧទ្ទិសកុសលផលបុណ្យ ប្រគេនចំពោះអតីតសម្តេចព្រះសង្ឃរាជទាំង១ ៨ ព្រះអង្គនៃព្រះរាជាណាចក្រថៃ ក្នុងយុគសម័យបាងកក រាប់បញ្ចូលទាំងព្រះឧបជ្ឈាយ៍និងគ្រូបាអាចារ្យទាំងឡាយរបស់សម្តេច។ សម្តេចក៏បានកសាងសាលារៀន និងជួសជុលវត្តអារាម ដើម្បីឧទ្ទិសនូវរាល់សកម្មភាពទាំងនោះចំពោះព្រះឧបជ្ឈាយ៍ លោកឪ ឌី នៃវត្តទេវសង្ឃារាមផងដែរ។

ជាការរំលឹកដល់ព្រះឧបជ្ឈាយ៍ទី២របស់ព្រះអង្គ ព្រះសង្ឃរាជទី១ ៣ សម្តេចក្រុមហ្លួងវជិរញាណវង្ស នៃវត្តបវរនិវេស, សម្តេចទ្រង់បានកសាងអាគារមួយខ្នងដោយដាក់ព្រះនាមរបស់ព្រះអង្គ។ ព្រះមហាក្សត្រថៃក្នុងអតីតកាលគ្រប់ព្រះអង្គត្រូវបានចងចាំតាមរយៈគម្រោងអាគារអនុស្សាវរីយ៍ រាប់បញ្ចូលទាំងការកសាងសាលារៀន មន្ទីរពេទ្យនានា និងបូជនីយស្ថាននៃព្រះបាទសម្តេចព្រះរាមា ទី៥ នៅខេត្តកាញ្ចនបុរី។

ក្នុងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះព្រះមាតា សម្តេចបាននាំព្រះមាតារបស់ព្រះអង្គមកកាន់ទីក្រុងបាងកក រួចក៏បានកសាងកូនតូបព័ណសមួយស្ថិតនៅក្បែរមហាកុដិ របស់ព្រះអង្គក្នុងវត្តបវរនិវេស។ ព្រះមាតារបស់ព្រះអង្គបានស្នាក់នៅទីនោះរហូតដល់ពេលគាត់ធ្វើអនិច្ចកម្ម។ ព្រះអង្គក៏បានបង្កើតមូលនិធិមួយមានឈ្មោះថា មូលនិធិ ណយ គជវត្រ (Noi Gajavatra Foundation) ទុកជាអនុស្សាវរីយ៍ចំពោះមាតាបិតារបស់ព្រះអង្គ។ មូលនិធិនេះបានផ្តល់អាហារូបករណ៍ដល់ការសិក្សារបស់ភិក្ខុ សាមណេរ និងយុវជន-យុវនារីទាំងឡាយ

សារៈសំខាន់ខ្លាំងណាស់ចំពោះមនុស្ស។ សម្តេចតែងមានថេរដីកាថា “ខ្ញុំគ្មានឱកាសបន្តការសិក្សាដល់កម្រិតឧត្តមដូច្នេះខ្ញុំចង់ផ្តល់ឱកាសបែបនេះដល់អ្នកដទៃនៅពេលណាដែលខ្ញុំអាចធ្វើទៅបាន”។

ការឱនលំទោននិងការគោរព

ផ្នែកមួយនៃអត្តចរិតរបស់សម្តេចដែលមិនដែលផ្លាស់ប្តូរនោះគឺ ការគោរពចំពោះព្រះមហាថេរៈដែលជាវៀមច្បង ពីព្រោះព្រះអង្គទ្រង់ត្រិះរិះថា ការគង់នៅច្រើនវស្សាក្នុងផ្នួសគឺជាកត្តាបង្ហាញនូវភាពចាស់ទុំយ៉ាងសំខាន់។ ទោះបីព្រះអង្គត្រូវបានតែងតាំងជាសម្តេចព្រះសង្ឃរាជនៃប្រទេសទាំងមូលក៏ដោយ ក៏សម្តេចនៅតែគោរពចំពោះព្រះមហាថេរដែលជាវៀមច្បងចាស់វស្សាជាងព្រះអង្គ។ នៅពេលដែលព្រះអង្គទ្រង់បានជ្រាបថាមានព្រះមហាថេរអាគន្តុកៈបួសចាស់វស្សាជាងព្រះអង្គនិមន្តមកជួប សម្តេចបាននិមន្តព្រះមហាថេរទាំងនោះគង់លើអាសនៈខ្ពស់ជាង។ បន្ទាប់មកព្រះអង្គក៏បានថ្វាយបង្គំព្រះមហាថេរទាំងនោះដោយសេចក្តីគោរពតាមតក្រិត្យក្រមដែលមានចែងក្នុងកិច្ចវត្តពុទ្ធសាសនា។ ជាមួយព្រះសង្ឃដែលមានវស្សាខ្ចី សម្តេចតែងតែទទួលស្វាគមន៍យ៉ាងរាក់ទាក់ប្រកបដោយមេត្តានិងករុណា។

គ្រូជាទីស្រឡាញ់

ចំណង់ចំណូលចិត្តចំពោះការសិក្សាវៀនសូត្រ និងការស្រឡាញ់របស់ព្រះអង្គចំពោះការចែករំលែកចំណេះដឹងដល់អ្នកដទៃ គឺគេបានដឹងយ៉ាច្បាស់គ្រប់ៗគ្នា។ សម្តេចមានបេះដូងជាគ្រូយ៉ាងពិតប្រាកដ ព្រះអង្គតែងតែចង់ចែករំលែកចំណេះដឹងល្អៗដល់សិស្សានុសិស្សរបស់ព្រះអង្គ ដោយប្រាថ្នាឱ្យពួកគេទទួលបាននូវអ្វីដែលព្រះអង្គផ្តល់ឱ្យ។

ជាមួយនឹងវាចាដ៏ផ្អែមល្ហែម សម្តេចទ្រង់មានថេរដីកាច្បាស់ៗនៅពេលដែលព្រះអង្គបង្រៀនព្រះធម៌ ហើយបញ្ចប់ការបង្រៀននានាទៀងពេលវេលាជានិច្ច ដោយមិនចាំបាច់មានទាឡិកាកំណត់ម៉ោងឡើយ។ ព្រះអង្គតែងតែបញ្ជាបអ្នកនៅជិតក្បែរព្រះអង្គឱ្យទទួលបាននូវការបង្រៀននេះ ជាពិសេស តាមរយៈការប្រព្រឹត្តប្រកបដោយសីលធម៌និងក្តីស្រឡាញ់របស់ព្រះអង្គ។

ភាពសាមញ្ញប្រកបសេចក្តីស្ងប់

សម្តេចរស់នៅយ៉ាងសាមញ្ញ តែងតែសុភាពរាបសារ, ប្រកបដោយខន្តី និងមិនជាប់ជំពាក់នឹងទម្រង់ប៉ែបបទពិធីការ ដែលបានក្លាយជាផ្នែកមួយនៃជីវិតរបស់ព្រះអង្គជាសម្តេចព្រះសង្ឃរាជ។ ក្នុងព្រះរាជដំណាក់របស់ព្រះអង្គគ្មានការតុបតែងពិសេសអ្វីឡើយ។ គ្មានរបស់របរមិនចាំបាច់ស្ថិតនៅរាយប៉ាយក្នុងបន្ទប់របស់ព្រះអង្គ។ ព្រះអង្គទ្រង់បានបង្រៀនភិក្ខុ-សាមណេរទាំងឡាយថា “ភិក្ខុ-សាមណេរទាំងឡាយមិនគប្បីរស់នៅបែបជីវិតឆើតឆាយនោះឡើយ។ ការលះបង់ជីវិតឃរាវាស ចូលមកបួសជាបព្វជិត បុគ្គលត្រូវតែលះបង់ចោលនូវអ្វីដែលមិនចាំបាច់”។

សម្តេចសព្វព្រះទ័យប្រើប្រាស់នូវចីវរចាស់ជាងចីវរថ្មី ហើយក៏សព្វព្រះទ័យបោក និងដេរស្បង់ចីវររបស់ព្រះអង្គដោយអង្គឯងផ្ទាល់ផងដែរ។ ភិក្ខុ-សាមណេរទាំងឡាយត្រូវបានណែនាំឱ្យប្រើប្រាស់ធនធានរបស់វត្តដោយការសន្សំសំចៃ។ រាល់អតិរេកលាភដែលពុទ្ធបរិស័ទបានប្រគេន ត្រូវតែចែកចាយដល់អ្នកដែលមានតម្រូវការពិតប្រាកដ ឧទាហរណ៍ នៅក្រោយរដូវចូលព្រះវស្សា។

នៅពេលមួយនោះ មានឡានដ៏មានតម្លៃមួយគ្រឿងត្រូវបានប្រគេនចំពោះសម្តេចដើម្បីប្រើប្រាស់ដោយផ្ទាល់ព្រះអង្គ។ ព្រះអង្គមានឆ្លើយថា “មិនមានកន្លែងសម្រាប់ចតទេ”,ដោយមិនធ្វើឱ្យពុទ្ធបរិស័ទអាក់អន់ស្រពន់ចិត្តក្នុងខណៈពេលព្រះអង្គបដិសេធនូវគ្រឿងសក្ការៈដ៏ប្រណិត។នៅក្នុងការប្រារព្ធពិធីបុណ្យនានានៅឯវត្តដទៃៗព្រះចៅអធិការនៃវត្តទាំងនោះតែងតែប្រគេននូវចំណែកនៃការបូជារបស់ពុទ្ធបរិស័ទនានាថ្វាយដល់សម្តេចជានិច្ច។ សម្តេចតែងតែទទួលយកនូវការប្រគេននោះ រួចហើយវេរទៅវិញភ្លាមៗ ដោយមានវេរដីកាថា “ខ្ញុំកូណាសូមចូលរួមចំណែកបំពេញបុណ្យកុសលជាមួយនឹងលោកម្ចាស់ផងដែរ”។

គុណធម៌ទាំងឡាយដែលសម្តេចជាអម្ចាស់បានបណ្តុះឡើងហើយ បានធ្វើឱ្យព្រះអង្គទទួលបានជោគជ័យក្នុងជីវិត។ គុណធម៌ទាំងនេះបានជួយព្រះអង្គឱ្យរួចផុតពីសេចក្តីលំបាក និងការខកចិត្តទាំងឡាយ ដែលតែងតែកើតមានក្នុងជីវិតលោកិយនេះ។ ជីវិតរបស់ព្រះអង្គបានជាគំរូដ៏ប្រសើរសម្រាប់មនុស្សគ្រប់រូបយកតម្រាប់តាម។

"បុគ្គលគ្រប់រូបប្រាថ្នាចង់បានសេចក្តីសុខសប្បាយ និងរួចផុតចាកទុក្ខ ប៉ុន្តែ ពួកគេខកខានមិនបានប្រតិបត្តិធម៌ដែលជាហេតុនាំមកនូវសេចក្តីសុខ និងបញ្ចប់នូវសេចក្តីទុក្ខ។ តើលទ្ធផលដែលបុគ្គលប្រាថ្នានោះអាចកើតឡើងបានយ៉ាងម៉េចកើត?"។
(កុសលធម៌បញ្ញាស្មី)

"មេត្តានិងសីល តែងតែជាប់គ្នាតែមួយ។ គេពិចារណាធម៌ទាំងពីរនេះដោយឡែកគ្នាណាស់។ បុគ្គលមានសីលរមែងស្តែងចេញនូវមេត្តានិងករុណា។ ហើយចំណែកឯបុគ្គលដែលមានមេត្តា និង ករុណា ជាការពិតគឺជាមនុស្សមានសីល"។

"គំនិតមួយដែលបុគ្គលគប្បីបណ្តុះជាំជារឿយៗនោះគឺគាពល្មមគ្រាន់ ដោយដឹងថាខ្លួនមានបានគ្រប់គ្រាន់។ បុគ្គលទាំងឡាយដែលដឹងច្បាស់នូវគាពល្មមគ្រាន់ គឺរស់នៅក្នុងសុភមង្គល។ បុគ្គលដែលមិនដឹងថា ខ្លួនមានបានគ្រប់គ្រាន់ ប្រៀបដូចជាបុគ្គលដែលត្រូវភ្លើងនេះ។ គាពមិនល្មមគ្រាន់ (ចង់បានមិនឈប់ឈរ) អាចកើតមាននៅក្នុងចិត្តរបស់អ្នកមានស្តុកស្តម្ភ។ គាពល្មមគ្រាន់ (គាពពេញចិត្តជាមួយនឹងអ្វីដែលខ្លួនមាន) អាចឃើញមាននៅក្នុងចិត្តរបស់អ្នកក្រ។ នេះគឺដោយសារ គាពល្មមគ្រាន់ និងគាពមិនល្មមគ្រាន់ គឺជារឿងរបស់ចិត្ត។ ហេតុដូច្នេះហើយ អ្នកមានទ្រព្យធនស្តុកស្តម្ភ ដែលជាបុគ្គលមិនដែលពេញចិត្តជាមួយនឹងអ្វីដែលខ្លួនមាននោះ គឺជាអ្នកក្រជានិច្ច. ឯអ្នកក្រវិញដែលជាបុគ្គលពេញចិត្តនឹងអ្វីដែលខ្លួនមាន គឺជាអ្នកមានជានិច្ច"។

(គាពល្មមគ្រាន់គឺជារឿងរបស់ចិត្ត)

គិក្ខុប្រកបដោយករុណា

"អាគារនិងទីតាំងទាំងឡាយ ដូចជា វត្តអារាម សាលាដៀន និងមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាល ដែលបានកសាងឡើងដោយសប្បុរសជននានាដើម្បីប្រយោជន៍ដល់អ្នកដទៃ គឺបង្ហាញអំពីសន្តានចិត្តមេត្តារបស់អ្នកទាំងនោះចំពោះអ្នកដទៃ។ ករុណាគឺសេចក្តីប្រាថ្នាចង់ឲ្យអ្នកដទៃផ្តងផុតសេចក្តីទុក្ខ។ នៅពេលបុគ្គលបានឃើញនូវការឈឺចាប់របស់អ្នកដទៃ ហើយបេះដូងរបស់គេញាប់ញ័រដោយការបារម្ភចំពោះពួកគេ បុគ្គលនោះនឹងមានចិត្តចង់ជួយពួកគេឲ្យរួចផុតចាកសេចក្តីទុក្ខ។ ដូច្នេះ ករុណាផ្ទុយគ្នានឹង វិហិង្សា (ភាពឃោរឃៅ)"។

"អ្វីដែលអាចជួយសម្រាលការឈឺចាប់និងសេចក្តីទុក្ខលំបាករបស់អ្នកដទៃ ដូចជាការកសាងមន្ទីរពេទ្យ សុទ្ធតែផ្ទុះបញ្ចាំងនូវករុណារបស់អ្នកកសាង"។

(ការរស់នៅសាមញ្ញ សេចក្តីសុខសាមញ្ញ)

ដោយសារករុណាជាធម្មជាតិរបស់ព្រះអង្គ សម្តេចតែងតែជួយសម្រាលការឈឺចាប់និងសេចក្តីទុក្ខលំបាករបស់អ្នកដទៃជានិច្ច។ ព្រះអង្គតែងតែយកព្រះទ័យទុកដាក់ចំពោះសុខមាលភាពប្រជាពលរដ្ឋ និងសុភមង្គលនៃប្រជាជាតិ។ ការដំកល់ព្រះធម៌ឲ្យតាំងនៅក្នុងដួងចិត្តរបស់មនុស្ស ហើយបង្រៀនឲ្យពួកគេរស់នៅប្រកបដោយភាពសុខ ដុមរម្យនាជាមួយអ្នកដទៃដោយសេចក្តីស្រឡាញ់គិតគូរអំពីគ្នានឹងគ្នា នឹងកសាងបានន្លូវការរួបរួមសាមគ្គីនិងការអាណិតអាសូរគ្នានៅក្នុងគ្រួសារនិងសង្គមជាតិរបស់ពួកគេ។

សម្តេចអង្គឯងផ្ទាល់បានត្រួសត្រាយបំភ្លឺផ្លូវ និងដឹកនាំប្រជាពុទ្ធបរិស័ទឲ្យមានជីវិតប្រកបសុខសន្តិភាព ដោយ

បានផ្សព្វផ្សាយនូវមេត្តាចិត្តចំពោះអ្នកដទៃដោយមិនមានភាពលំអៀង។ ជាពិសេស ព្រះអង្គផ្តោតព្រះទ័យចំពោះអ្នកដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធច្រើនប្រភេទដែលបានជាប្រយោជន៍ដល់ពួកគេ។ គម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងនោះមានដូចជា៖

-សាលារាមានិយខេត្ត ព្រះបាទសម្តេច រាម ទី៥ ស្ថិតនៅក្នុង ខេត្តកាញ្ចនបុរី សម្រាប់សិស្សក្រីក្រគោកយ៉ាក, រួមទាំងមន្ទីរពេទ្យដែលមានឈ្មោះដូចគ្នា ដែលស្ថិតនៅក៏ក្បែរសាលា។

-មន្ទីរពេទ្យវត្តញាណសំវរារាម ក្នុងខេត្តជលបុរី សម្រាប់ព្រះសង្ឃ និងគ្រហស្ថ

- អាគារព្រះសង្ឃរាជ ឬ អាគារសាកលមហាសង្ឃបរិនាយក ដែលមានចំនួនទាំងអស់ចំនួន១៩។ អាគារនីមួយៗតាំងនៅក្នុងមន្ទីរពេទ្យ ដែលស្ថិតនៅពាលពេញព្រះរាជាណាចក្រថៃ។ ក្រៅពីកសាងដើម្បីឧទ្ទិសថ្វាយចំពោះសម្តេចព្រះសង្ឃរាជទាំង១៩អង្គ នៃប្រទេសថៃ អាគារទាំង១៩នេះក៏បម្រើការអប់រំព្រមទាំងសេវាកម្មវេជ្ជសាស្ត្រដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ ដែលនៅខ្វះសេវាបែបនេះផងដែរ។

-អាគារពាខ្នងបន្ថែម សម្រាប់សេវាកម្មវេជ្ជសាស្ត្រនៅក្នុងមន្ទីរពេទ្យចូឡាឡុងកនទីក្រុងបាងកកគឺ: អាគារវជិរញ្ញាណវង្ស, អាគារវជិរញ្ញាណសាមគ្គីព្យាបាល និង អាគារ ភ.ប.រ ។

នៅពេលប្រទេសជាតិជួបប្រទះនឹងគ្រោះធម្មជាតិ សម្តេចទ្រង់បានធ្វើសកម្មភាពយ៉ាងរហ័សដើម្បីជួសជុលនិងជួយជនរងគ្រោះ។ ឧទាហរណ៍ នៅពេលមានទឹកជំនន់នៅទីណា ព្រះអង្គទ្រង់បានផ្តល់គ្រឿងឧបភោគបរិភោគ ថ្នាំពេទ្យ និងការជួយសង្គ្រោះដល់ជនរងគ្រោះទាំងនោះជួនកាល យាងទៅចែកគ្រឿងផ្គត់ផ្គង់ទាំងនោះដោយផ្ទាល់ព្រះអង្គដល់ទីកន្លែងរងគ្រោះ។

នៅថ្ងៃទៅ១៤ ខែតុលា ឆ្នាំ១៩៧៣, នៅពេលដែលនិស្សិតសាកលវិទ្យាល័យធ្វើបាតុកម្មបង្ហាញនូវកាមិនពេញចិត្តរបស់ពួកគេចំពោះរាជរដ្ឋាភិបាល, ក្រុមនានាបាន វាយប្រហារនិស្សិតទាំងនោះទាំងកំរោល នៅឯទីលានព្រះរុម និងនៅតាមបណ្តោយផ្លូវ រាជដំណើរ។ សម្តេចបានសរសេរនូវសារលិខិតមួយលើកទឹកចិត្តមនុស្សគ្រប់រូបឲ្យរក្សាឯកភាពជាតិព្រះអង្គបានថតចម្លង



សារលិខិតទាំងនោះ ហើយបានចែកចាយដើម្បីធ្វើឲ្យការផ្ទុះអំពើហិង្សាទាំងនោះមានភាពស្ងប់ស្ងាត់ និងកាត់បន្ថយការខូចខាតបន្តទៀត។

នៅក្នុងឆ្នាំ១៩៩១, អគ្គីភ័យមួយបានឆាបឆេះលំនៅដ្ឋានប្រជាពលរដ្ឋនៅខាងក្រោយវត្តបវរនិវេស នាពាក់កណ្តាលអាធ្រាត្រ។ ឧបទ្ទវហេតុបានកើតឡើងនៅមិនឆ្ងាយពីព្រះមហាកុដិរបស់សម្តេចគង់នៅ។ ប្រជាពលរដ្ឋទាំងឡាយបានឆោឡោយ៉ាងខ្លាំងដោយសារអណ្តាតភ្លើងចេះតែឆេះរាលដាលទៅ។ ដូច្នេះ សិស្សគណជិតដិតរបស់ព្រះអង្គមានការព្រួយបារម្ភអំពីសុខមាលភាពរបស់ព្រះអង្គ បានសុំយាងសម្តេចទៅគង់នៅអាគារមានសុវត្ថិភាព។ ប៉ុន្តែ សម្តេចទ្រង់មានព្រះទ័យបារម្ភយ៉ាងខ្លាំងអំពីសុខមាលភាពប្រជាពលរដ្ឋ ព្រះអង្គទ្រង់បានយាងទៅជួយប្រជាពលរដ្ឋភ្លាមៗ ដោយបានប្រាប់ឲ្យពួកគេរក្សាភាពស្ងប់ស្ងៀមកុំមានការភ័យតក់ស្លុត និងឲ្យពួកគេបើកផ្លូវឲ្យអ្នកពន្លត់អគ្គីភ័យចូល។ សម្តេចក៏បានអនុញ្ញាតឲ្យពួកគេមកស្នាក់នៅក្នុងវត្តរហូតដល់ពេលពួកគេមានកន្លែងស្នាក់នៅ។

នៅក្នុងឆ្នាំ១៩៩៧ នៅពេលដែលមានវិបត្តិសង្គកិច្ច (តុំយ៉ាំគុង), សម្តេចបាននិមន្តទៅបិណ្ឌបាត្រនៅក្នុងតំបន់ជាច្រើនជុំវិញទីក្រុងបាងកកដើម្បីលួងលោមប្រជាជន ហើយបានផ្តល់នូវក្តីសង្ឃឹមដល់ពួកគេនៅក្នុងគ្រាទុក្ខលំបាកនោះ។

រាល់ពេលប្រទេសជាតិមានវិបត្តិ, សម្តេចទ្រង់មានព្រះថេរដីកាទៅកាន់ព្រះសង្ឃទូទាំងប្រទេសឲ្យធ្វើពិធីសូត្រធម៌បួងសួងដើម្បីជួយគាំទ្រខាងផ្លូវស្មារតីដល់ប្រជាជន។ ឧទាហរណ៍, នៅពេលព្រះមហាក្សត្រព្រះអង្គទ្រង់ប្រឈួន សម្តេចតែងតែបានឲ្យព្រះសង្ឃទូទាំងប្រទេសប្រារព្ធពិធីសូត្រធម៌ថ្វាយព្រះរាជកុសល ដើម្បីជួយព្រះអង្គឲ្យជាសះស្បើយពីរោគាពាធ។

ទោះបីជាទូទៅសម្តេចទ្រង់មិនបានយល់ព្រមឲ្យធ្វើវត្ថុស័ក្តិសិទ្ធិ ព្រះអង្គតែងតែអនុញ្ញាតឲ្យអ្នកដទៃធ្វើបែបនោះ ប្រសិនបើវាជារឿងដែលបម្រើប្រយោជន៍

សាធារណៈ។ ប្រសិនបើមានគេនិមន្តសម្តេចទៅចូលរួមពិធីពុទ្ធាភិសេកឬពិធីអភិសេកវត្ថុស័ក្តិសិទ្ធិ ព្រះអង្គតែងប្រសិទ្ធនាមពិធីជួបជុំនោះថា “ពិធីអធិដ្ឋានចិត្ត” ដើម្បីតម្រង់ចិត្តអ្នកចូលរួមឆ្ពោះទៅរកត្រៃសរណគមន៍ ពោលគឺ: ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ ព្រះអង្គក៏សព្វព្រះទ័យឲ្យគេឆ្លាក់អក្សរកាត់នៃនាមព្រះអង្គ “NYSS” នៅលើវត្ថុស័ក្តិសិទ្ធិឬបដិមាទាំងឡាយ ប្រសិនបើវាជួយឲ្យប្រជា

2015 : His Holiness' compassionate relief for Earthquake in Nepal

2008 : His Holiness sent over relief goods for victims of Nargis in Myanmar

2009 : His Holiness' compassionate relief for flood victims in Bangkok

ពលរដ្ឋរួបរួមគ្នាក្នុងគោលបំណងល្អ។

ការអារាធនានិមន្តចូលរួមពិធីអធិដ្ឋានចិត្តមានចំនួនកាន់តែច្រើនឡើងៗ ខណៈពេលសមត្ថភាពផ្នែកសមាធិរបស់សម្តេចមានភាពល្បីល្បាញដូចសមត្ថភាពបង្រៀនព្រះធម៌របស់ព្រះអង្គដែរ។ ដោយសេចក្តីករុណាចំពោះប្រជាពលរដ្ឋ ជារឿយៗព្រះអង្គទទួលយកសំណូមពររបស់ពួកគេ រួមទាំងការនិមន្តទៅប្រសិទ្ធពរជ័យពិធីមង្គលការ ចូលរួមពិធីបុណ្យសព ពិធីសម្ពោធហាងថ្មី ការសម្ពោធនាវា ឬពិធីដាក់ឱ្យដំណើរការយន្តហោះក្រុមហ៊ុនអាកាសចរណ៍ជាតិ និងពិធីផ្សេងៗទៀត។

សម្តេចយល់ឃើញថា ការចែករំលែកបញ្ញាញាណតាមរយៈការយល់ដឹងព្រះធម៌ (ធម្មសញ្ញា) គឺជារង្វាន់ដ៏មានតម្លៃសម្រាប់ប្រជាពលរដ្ឋ។ ប៉ុន្តែ ការជម្រុញឱ្យប្រជាជនចូលចិត្តព្រះធម៌ទាមទារឱ្យមានវិធីសាស្ត្រដែលមានការគិតគូរល្អិតល្អន់។ នៅពេលដែលប្រជាពលរដ្ឋមកកាន់វត្តអារាមដើម្បីថ្វាយបង្គំសម្តេចព្រះអង្គតែងតែប្រទានដល់ពួកគេនូវព្រះពុទ្ធរូបតូចៗជាមួយនឹងកូនសៀវភៅដែលសម្តេចបានតែងនិពន្ធឡើងដែលហាក់ដូចជាប្រទានសារថា “តម្កល់ព្រះពុទ្ធរូបនៅក្បែរខ្លួនអ្នក ហើយតម្កល់ព្រះធម៌នៅក្បែរបេះដូងរបស់អ្នក”។ ដូច្នេះ មេត្តានិងករុណារបស់ព្រះអង្គបានផ្សព្វផ្សាយទៅកាន់មនុស្សគ្រប់គ្នាដោយឥតរើសមុខ។ សម្តេចបដិបត្តិព្រះធម៌ពិតៗ ហើយមានព្រះជន្មរស់នៅដើម្បីអ្នកដទៃ។ ព្រះអង្គគឺជាគំរូរស់សម្រាប់អ្នកដទៃ ជាអង្គដែលបានបង្ហាញនូវកំណប់ទ្រព្យនៃសេចក្តីសុខស្ងប់ផ្លូវចិត្តហើយព្រះអង្គប្រើប្រាស់ឧបាយកោសល្យក្នុងការតម្រង់ធនធានផ្លូវកាយនិងផ្លូវចិត្តរបស់ព្រះអង្គដើម្បីសេក្តីសុខរបស់អ្នកដទៃ។

ព្រះអគ្គសង្ឃរាជ

"ខ្ញុំបានជួបសម្តេចព្រះសង្ឃរាជជាច្រើនឆ្នាំកន្លងទៅ ហើយមានសេចក្តីគោរព និងកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការបំពេញតួនាទីនិងភារកិច្ចផ្នែកសាសនារបស់ព្រះអង្គ។ ពេញមួយជីវិតដ៏វែងនិងមានអត្ថន័យរបស់ព្រះអង្គ សម្តេចតែងតែបូជាកម្លាំងកាយចិត្តក្នុងការបម្រើមនុស្សជាតិ"។

(សម្តេច ងាឡៃ ឡាមា ទី១៤)

"វីរិយភាពដ៏ស្មោះស្ម័គ្រ និងភាពជោគជ័យដ៏ធំធេងរបស់សម្តេច ពិតជាមានតម្លៃដ៏ស័ក្តិសមក្នុងការទទួលបានឋានៈគោរមងារកិត្តិយសជា សម្តេចព្រះសង្ឃរាជនៃព្រះពុទ្ធសាសនាពិភពលោក, ដែលត្រូវបានគេគោរពកោតសរសើរ ព្រមទាំងមានរស្មីចែងចាំងនៅក្នុងប្រវត្តិសាព្រះពុទ្ធសាសនាជាដរាបរហូត"។

(ព្រះតេជគុណ បណ្ឌិត ក្សេម អ៊ីនស៊ុនជោ)

ចាប់តាំងពីថ្ងៃដែលព្រះអង្គបានចូលបព្វជាជាសាវ័ករបស់ព្រះពុទ្ធមក សម្តេចព្រះញាណសំវរៈ ព្រះសង្ឃរាជទ្រង់បានបដិបត្តិតាមព្រះធម៌វិន័យដោយសទ្ធាយ៉ាងម៉ុតមាំ។ សម្តេចបានសិក្សាព្រះធម៌យ៉ាងយកព្រះទ័យទុកដាក់ និងបដិបត្តិតាមព្រះវិន័យ៉ាងខ្ជាប់ខ្ជួន ដូចជាសមាធិយោគាវចរ ដែលស្វែងរកការយល់ដឹងអំពីមាតិកានិងជីវិតតាមរយៈការចម្រើនវិជ្ជានិងចរណៈ។ ព្រះអង្គបានខ្នះខ្នែងបង្រៀនទ្រឹស្តីព្រះធម៌ និងការបដិបត្តិសមាធិដល់បព្វជិតនិងគ្រហស្ថ ទាំងថៃនិងបរទេស នៅក្នុងវត្ត នៅក្នុងសាលាវៀន និងតាមរយៈការផ្សព្វផ្សាយតាមវិទ្យុទូទាំងប្រទេសទៀតផង។ ដូចគ្នានេះដែរ ព្រះអង្គបានបង្រៀនព្រះពុទ្ធសាសនាជាភាសាអ្នកស្រុកដល់សាធារណៈជន តាមរយៈការបដិបត្តិជាគំរូការទេសនា និងការសរសេរ។ ក្នុងឋានៈជាប្រមុខសង្ឃនៃប្រទេសថៃ ព្រះអង្គបានចាត់ចែងកិច្ចការសង្ឃយ៉ាងមានប្រសិ



(From left) the Most Ven. Dr. Kyuse Enshinjoh, His Holiness the Dalai Lama, His Holiness, Tokyo, Japan.

ទ្ធភាព។

នៅក្នុងប្រទេសជាច្រើន សម្តេចទ្រង់បានជួយព្រះពុទ្ធសាសនាឲ្យរស់រានឡើងវិញ និងបានលើកទឹកចិត្តឲ្យបង្កើតការទាក់ទងគ្នាក្នុងចំណោមពុទ្ធបរិស័ទទូទាំងពិភពលោក។ សម្តេចមានសេចក្តីករុណាបង្កើតនូវមជ្ឈមណ្ឌលសិក្សាអប់រំនិងមន្ទីរពេទ្យជាច្រើន។ ករុណាធម៌របស់សម្តេចបានផ្សព្វផ្សាយទៅយ៉ាងទូលំទូលាយចំពោះជនរងគ្រោះទាំងឡាយទាំងនៅក្នុងប្រទេសថៃ និងនៅក្នុងប្រទេសដទៃ។

សកម្មភាពទាំងនេះមិនមែនជាឧបទ្ទវហេតុចៃដន្យនៅក្នុងជីវិតរបស់សម្តេចឡើយ ព្រោះថា ព្រះអង្គបានបូជាពេញមួយជីវិតដើម្បីមនុស្សទូទៅ។ តាមន័យនេះ ជាការពិត សម្តេចគឺជា “ព្រះសង្ឃរបស់ប្រជាជន” ដែលមានវត្តមាននិងព្រះទ័យពោរពេញទៅដោយមេត្តាករុណាចំពោះសព្វសត្វទាំងអស់ គ្រប់ទីកន្លែង។

ក្នុងព្រះជន្មាយុ៩០ព្រះវស្សា ក្នុងឆ្នាំ២០០០, សុខភាពផ្លូវកាយរបស់សម្តេចកាន់តែចុះខ្សោយ ហើយក៏ត្រូវបានគេបញ្ជូនទៅកាន់អាគារសាមគ្គីព្យាបាលក្នុងមន្ទីរពេទ្យអនុស្សាវរីយ៍ ព្រះបាទ ចូឡាឡុងកន ដើម្បីទទួលការព្យាបាលឲ្យបានត្រឹមត្រូវ។ គ្រាដំបូង សម្តេចនិមន្តត្រឡប់ទៅវត្តបវរនិវេសវិហារម្តងម្កាល ដើម្បីចូលរួមធ្វើឧបោសថនៅរៀងរាល់ថ្ងៃ១៥កើត និង១៥រោច នៅឧបោសថាគារ។ លុះសម័យកាលក្រោយមក នៅពេលសុខភាពរបស់សម្តេចចុះខ្សោយ វេជ្ជបណ្ឌិតបាននិមន្តសម្តេចឲ្យគង់នៅក្នុងមន្ទីរពេទ្យដើម្បីទទួលការព្យាបាលជាប់លាប់ជាជាងនិមន្តទៅមកដូច្នេះ។ បន្តបន្ទាប់មកទៀត ចាប់ពីឆ្នាំ២០០៧ មក សម្តេចត្រូវគង់ព្យាបាលនៅមន្ទីរពេទ្យជាអចិន្ត្រៃយ៍។

ក្នុងខណៈពេលដែលសម្តេចកំពុងតែទទួលការព្យាបាលនៅក្នុងមន្ទីរពេទ្យនោះ ពុទ្ធ

បរិស័ទទាំងឡាយបានរង់ចាំនូវដំណឹងអំពីស្ថានភាពអាគាពាធរបស់សម្តេចយ៉ាងអន្ទះអន្ទែង។ជារៀងរាល់ឆ្នាំនៅថ្ងៃទី៣ ខែតុលា ជាថ្ងៃខួបកំណើតរបស់សម្តេច ពុទ្ធបរិស័ទទាំងឡាយមកពីទីក្រុងបាងកក និងភូមិភាគខាងលើ បានមកកាន់វត្តបវរនិវេសវិហារ ដើម្បីបួងសួងប្រគេនពរថ្ងៃបុណ្យចម្រើនព្រះជន្មសម្តេច។ ជារៀងរាល់ឆ្នាំមនុស្សរាប់រយរាប់ពាន់នាក់ចុះឈ្មោះរបស់ពួកគេដើម្បីថ្វាយព្រះពរជ័យថ្ងៃបុណ្យចម្រើនព្រះជន្មសម្តេច។ មនុស្សណាដែលអាចធ្វើដំណើរទៅមន្ទីរពេទ្យដោយខ្លួនគេផ្ទាល់ ពួកគេក៏បានទៅថ្វាយបង្គំប្រគេនពរសម្តេចដោយផ្ទាល់។ ប្រជាពុទ្ធបរិស័ទមានការនឹករលឹកអំពីមេត្តាករុណា និងការអប់រំរបស់សម្តេច។ ការអប់រំរបស់សម្តេចគឺមាននៅគ្រប់ទីកន្លែងទាំងអស់, ទាំងនៅក្នុងសៀវភៅ និងទាំងនៅតាមប៉ុស្តិ៍វិទ្យុ និងដីស CD/DVD។ ប្រជាពុទ្ធបរិស័ទនៅតែបន្តអានសៀវភៅរបស់សម្តេចដើម្បីដាស់នូវសតិសម្បជញ្ញៈ ក្នុងការជម្រុះចិត្តឲ្យអស់ភាពសៅហ្មងទាំងឡាយ។

ក្នុងឋានៈជាសម្តេចព្រះសង្ឃរាជគ្រងតំណែងយូរជាងគេនៃព្រះរាជាណាចក្រថៃអស់រយៈពេល២ ៤ ព្រះវស្សា សម្តេចបានយាងចូលដល់ព្រះជន្ម១០០ព្រះវស្សាក្នុងឆ្នាំ២០១៣។ ស្ថិតក្នុងឱកាសដែលមិនបានព្រាងទុកជាមុននេះ, ព្រះបាទសម្តេច ភូមិបុល អឌុលយាដេត បានព្រះរាជូបត្ថម្ភរៀបចំពិធីបុណ្យចម្រើព្រះជន្មព្រះវស្សាថ្វាយដល់សម្តេចព្រះញាណសំវរៈនៃព្រះរាជាណាចក្រថៃ ដែលបានរៀបចំធ្វើឡើងនៅក្នុងវត្តបវរនិវេសវិហារ។ ជាងនេះទៅទៀត ព្រះមហាក្សត្រីបានព្រះរាជានុញ្ញាតឲ្យ ព្រះអង្គម្ចាស់ក្សត្រី សម្តេចមហាចក្រី សិរិនធន ជាព្រះរាជតំណាងក្នុងព្រះរាជពិធីពិសេសមួយ ដែលប្រារព្ធធ្វើឡើងនៅព្រះមហាវិហារ វត្តព្រះកែវមរកត។

១ ០ ថ្ងៃបន្ទាប់ពីថ្ងៃបុណ្យចម្រើនព្រះជន្មវស្សាគម្រប់១ ០ ០ ព្រះវស្សា, ស្ថានភាពអាពាធរបស់សម្តេចកាន់តែធ្ងន់ទៅៗ។ បន្ទាប់ពីបានពិភាក្សាគ្នាអំពីករណីនេះរួច ក្រុមវេជ្ជបណ្ឌិតនានារបស់សម្តេច បានសម្រេចចិត្តរួមគ្នាថា សម្តេចត្រូវការការវះកាត់ពោះវៀនធំ និងពោះវៀនតូច។ ការវះកាត់ទទួលបានជោគជ័យ និងធ្វើឲ្យស្ថានភាពរបស់សម្តេចហ្នឹងហ្ន, តែទោះជាយ៉ាងណា ស្ថានភាពអាពាធទាំងស្រុងរបស់សម្តេចគឺមិនបានវិកចម្រើនល្អនោះឡើយ។ ជាតិពុលក្នុងឈាមបានបណ្តាលឲ្យសម្តាធឈាម និងចង្វាក់បេះដូងធ្លាក់ចុះយ៉ាងខ្លាំង។ នៅថ្ងៃទី២៤ ខែតុលា សម្តេចទ្រង់មិនបានឆ្លើយតបទៅនឹងថ្នាំពេទ្យទាល់តែសោះ ហើយប្រព័ន្ធដង្ហើមក៏កាន់តែធ្លាក់ចុះខ្សោយជាលំដាប់។ ទីបំផុត នៅម៉ោង៧.៣០ នាទីយប់ សម្តេចទ្រង់លែងដកដង្ហើមទាំងស្រុង។ ព្រះអង្គទ្រង់មានព្រះជន្មាយុ១០០ ព្រះវស្សា និង២១ថ្ងៃ។

ស្ថានីទូរទស្សន៍និងវិទ្យុទាំងអស់ទូទាំងប្រទេសបានប្រកាសនូវការផ្តែងជាផ្លូវការ ស្តីអំពីការយាងចូលទិវង្គតរប

ស់សម្តេចអម្ចាស់ ដែលធ្វើឡើងដោយក្រុមវេជ្ជបណ្ឌិត នៃមន្ទីរពេទ្យអនុស្សាវរីយ៍ ព្រះបាទសម្តេច ចូឡាឡុងកន។ នៅថ្ងៃបន្ទាប់ មនុស្សម្នាទាំងឡាយបានមកជួបជុំគ្នាដោយសេចក្តីទុក្ខក្រៀមក្រំនៅតាមដងផ្លូវ នៅពេលដែលព្រះសពត្រូវបានដង្ហែចេញពីមន្ទីរពេទ្យមកកាន់វត្ត។ មនុស្សគ្រប់វ័យ ទាំងចាស់ទាំងក្មេង សិស្ស និស្សិត បានមកចូលរួមកាន់ទុក្ខដោយលុតជង្គង់ក្រាបថ្វាយបង្គំ នៅខណៈដែលចរាចរកំពុងតែមមាញឹក។ ពួកគេស្លៀកសំលៀកបំពាក់កាន់ទុក្ខ គឺ: ពណ៌ខ្មៅឬពណ៌ស ។

ព្រះសពរបស់សម្តេចត្រូវបានដង្ហែជាក្បួនចេញពីមន្ទីពេទ្យមកកាន់វត្តបវរនិវេសវិហារ ដែលជាកន្លែងដែលព្រះអង្គធ្លាប់បានគង់នៅ។ កងរាជអាវុធហត្ថ និងក្រុមប៉ូលិស ដែលជាកងរក្សាព្រះអង្គរបស់ព្រះអង្គម្ចាស់ សម្តេច មហាវជិរឡុងកន ព្រះរាជទាយាទថៃ ស្ថិតក្នុងសំលៀកបំពាក់ពណ៌ស បានឈរជាអបសងខាងផ្លូវជារបងកិត្តិយស ចាប់តាំងពីប្រសព្វ វ៉ាន់ ឆ័ត្រ ដល់ វត្ត។ ក្រៅពីមន្ត្រីប្រដាប់អាវុធក៏មានក្រុមមនុ

ស្បថចូលរួមកាន់ទុក្ខជាច្រើនផងដែរ។ ព្រះរាជទាយាទបានចេញព្រះរាជបញ្ជាផ្ទាល់ព្រះអង្គទៅកាន់ មន្ត្រីបុគ្គលិកក្រោមឱវាទព្រះអង្គ ឱ្យចូលរួមក្នុងពិធីប្រគល់ព្រះសពនៅវត្តបវរនិវេសវិហារប្រកបដោយមហាកិត្តិយស និងការគួបតែងស្អាតល្អ។

នៅឯវត្តបវរនិវេសវិហារ មនុស្សម្នាទាំងឡាយបានរង់ចាំទទួលស្វាគមន៍ព្រះអង្គម្ចាស់សម្តេច មហាវជិរឡុងកន ព្រះរាជទាយាទថៃ ដែលបានយាងមកដល់វត្តបវរនិវេសវិហារ ដើម្បីធ្វើជាអធិបតីក្នុងព្រះរាជពិធីចម្ងាស (លាងសព) និងការថ្វាយបង្គុំលាជាចុងក្រោយ។

មិនទាន់បានមួយខែកន្លងផុតទៅផង ចាប់តាំងពីថ្ងៃបុណ្យចម្រើនព្រះជន្មសម្តេច គម្រប់ខួប១០០វស្សា បរិយាកាសដែលពោរពេញទៅដោយក្តីសប្បាយរីករាយ បានប្រែក្លាយទៅជាភាពសោកសៅ និងភាពអាឡោះអាល័យ។ អ្នកគោរពបូជាយ៉ាងច្រើនបានធ្វើដំណើរមកពីទីឆ្ងាយៗ។ ពុទ្ធបរិស័ទជាច្រើនទៀតមកថ្វាយបង្គុំរៀងរាល់ថ្ងៃគ្រប់ៗគ្នាបានថ្វាយបង្គុំចំពោះព្រះសពដោយសេចក្តីគោរពយ៉ាងក្រៃលែង ហើយសូធ្យធម៌ដើម្បី ឧទ្ទិសកុសលថ្វាយសម្តេចព្រះសង្ឃរាជ។

ព្រះមហាក្សត្រ ព្រះបាទសម្តេច ព្រះភូមិបុល អាឌុលយ៉ាដេត បានរាជានុញ្ញាតឱ្យសម្តេចព្រះមហាវជិរឡុងកនជាព្រះរាជតំណាងរបស់ព្រះអង្គយាងចូលរួមក្នុងព្រះរាជពិធីចម្ងាសព្រះសព។ ព្រះមហាក្សត្របានទទួលព្រះរាជពិធីក្បួនដង្ហែក្នុងពិធីបុណ្យព្រះសពរបស់សម្តេច ក្រោមព្រះរាជូបត្ថម្ភរយៈពេល៧ ថ្ងៃ។ ព្រះមហាក្សត្របានចេញព្រះរាជបញ្ជាឱ្យព្រះសង្ឃប្រារព្ធពិធីបុណ្យព្រះសពជារៀងរាល់យប់ថ្ងៃទៅ តាមលំអានប្រពៃណីក្សត្រពីបូរាណ។ លើសពីនេះទៀត ស្ថាប័នរដ្ឋ និងសាធារណៈទូទៅ បានឧបត្ថម្ភពិធីបុណ្យព្រះសពជារៀងរាល់ថ្ងៃក្នុងរ

យ:ពេលមួយឆ្នាំពេញ។ ជាមួយគ្នានេះផងដែរ ប្រជាពុទ្ធបរិស័ទគ្រប់ខេត្តក្រុងទាំងអស់បានប្រារព្ធពិធីបុណ្យឧទ្ទិសថ្វាយព្រះរាជកុសលដល់សម្តេចជាប់មិនដាច់។

ការកាន់ទុក្ខរបស់ប្រជាជនថៃត្រូវបានបញ្ចេញសំឡេងកងរំពងបន្ថែមទៀត តាម រយ:តំណាងប្រទេសនានា ប្រមុខរដ្ឋ ព្រមទាំងមេដឹកនាំសហគមន៍សាសនាពីបរទេសផងដែរ។ ឥស្សរជនជាច្រើនបានធ្វើដំណើរមកចូលរួមព្រះរាជពិធីបុណ្យសពរបស់សម្តេច និងចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំបំផុត។ អង្គទូតពីប្រទេសចំនួន២ ៣ បានមកចូលរួមនៅក្នុងព្រះរាជពិធីបុណ្យសព៧ ថ្ងៃរបស់សម្តេច។ រដ្ឋមន្ត្រីក្រសួងវប្បធម៌នៃសាធារណៈរដ្ឋឥណ្ឌា និងឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំប្រទេសថៃ បានប្រារព្ធពិធីវជ្រយានបូជា ដែលជាការដឹងគុណដ៏ខ្ពស់បំផុត ដើម្បីឧទ្ទិសថ្វាយព្រះរាជកុសលដល់ព្រះបដិសន្ធិវិញ្ញាណរបស់សម្តេច។ គណៈដឹកនាំជាន់ខ្ពស់នៃបុរីវ៉ាទីកង់ដឺហូលីស៊ី (The Holy See)តំណាងដោយសន្និសីទអភិបាលសាសនាកាតូលិកនៃប្រទេសថៃ (Catholic Bishops' Conference of Thailand) បានប្រារព្ធពិធីបួងសួងមហាជននិងពិធីសូធ្យធម៌បុណ្យសពដើម្បីឧទ្ទិសថ្វាយព្រះរាជកុសលដល់បដិសន្ធិវិញ្ញាណរបស់សម្តេច។ក្រុមពុទ្ធសាសនានិកាយចិននៃប្រទេសថៃ (Chinese Buddhist

Lineage of Thailand) បានរៀបចំពិធីបុណ្យសពកុងតេក ថ្វាយជាកិត្តិយសចំពោះសម្តេចផងដែរ។

នៅក្នុងប្រទេសជាច្រើន, ពិធីសូត្រធម៌ពិសេសតាមបែបពុទ្ធសាសនាត្រូវបានប្រារព្ធធ្វើឡើង ដើម្បីឧទ្ទិសកុសលដល់ព្រះបដិសន្ធិវិញ្ញាណរបស់សម្តេច មានដូចជា ប្រទេសមិកស៊ីក ប្រទេសស្រីលង្កា ប្រទេសជប៉ុន។ និកាយពុទ្ធសាសនា នេនប៊ុតស៊ុស៊ុ នៃប្រទេសជប៉ុន បានរៀបចំពិធីសូត្រធម៌បួងសួងគោរពវិញ្ញាណខន្ធយ៉ាងធំពិសេស ដែលមានព្រះសង្ឃចំនួន១០០០អង្គ នៅឯវត្តទីស្នាក់ការកណ្តាលរបស់ខ្លួន។

ព្រះតេជគុណ បណ្ឌិត ក្យូសេ អ៊ីនស៊ិនជោ ជាបព្វជិតស្ថានិកនៃនិកាយពុទ្ធសាសនា នេនប៊ុតស៊ុស៊ុ នៃប្រទេសជប៉ុន និងជាប្រធាននៃសន្និសីទកំពូលពុទ្ធសាសនាបានធ្វើដំណើរមកកាន់ប្រទេសថៃដើម្បីមកថ្វាយបង្គំព្រះសពសម្តេចជាលើកចុងក្រោយ។ នៅឯវត្តបវរនិវេសវិហារ ព្រះតេជគុណ អ៊ីនស៊ិនជោ បាននាំមកជាមួយនូវសាររំលែកទុក្ខពីប្រទេសសមាជិកចំនួន ១ ៧ នៃសន្និសីទកំពូលពុទ្ធសាសនា ក្នុងចំណោម៣ ៣ ប្រទេសសមាជិក, ជាពិសេស សាររំលែកទុក្ខពីប្រទេសបែលហ្ស៊ិក ហ្វាំងឡង់ ស្វីស មិចស៊ីក ចក្រភពអង់គ្លេស, សហរដ្ឋអាមេរិក និងនេប៉ាល់។ ព្រះតេជគុណក៏បានថ្លែងកោតសរសើរដល់សម្តេចថា ពិតជាសម្តេចព្រះសង្ឃរាជនៃពុទ្ធសាសនាពិភពលោក - “សម្តេចព្រះអគ្គសង្ឃរាជ”។

សម្តេចដាឡៃ ឡាម៉ា ប្រមុខដឹកនាំពុទ្ធសាសនាទីបេត៍ បានសំដែងនូវសមានទុក្ខតាមរយៈគេហទំព័ររបស់ព្រះអង្គ ហើយមានព្រះសង្ឃដីកាថា: “ការសុគតរបស់សម្តេច ធ្វើឲ្យយើងបាត់បង់នូវធម្មមិត្តដ៏គួរឲ្យគោរព។ ខ្ញុំបានជួបអតីតព្រះសង្ឃរាជជាច្រើនឆ្នាំកន្លងទៅ ហើយមានការគោរព និងការកោតស

រសើរយ៉ាងជ្រាលជ្រៅចំពោះការបំពេញតួនាទីនិងភារកិច្ចផ្នែកសាសនារបស់ព្រះអង្គ។ ពេញមួយជីវិតដ៏វែងនិងមានអត្ថន័យរបស់ព្រះអង្គ សម្តេចតែងតែបូជាកម្លាំងកាយចិត្តក្នុងការបម្រើមនុស្សជាតិ”។

ការពោលសរសើរបែបនេះគឺជាតួយ៉ាងបង្ហាញនូវការគោរពយ៉ាងជ្រាលជ្រៅពីពុទ្ធបរិស័ទជុំវិញពិភពលោក។ ជាការណ៍ពិត, វាគឺជាការកម្រក្រៃពេកណាស់ ដែលមេដឹកនាំពុទ្ធសាសនាមួយអង្គត្រូវបានគេទទួលស្គាល់ជា

សាកលថា ជាគំរូដ៏ក្រៃលែងនៃការគោរពបូជាបែបពុទ្ធសាសនា ដូចអតីតសម្តេចព្រះញ្ញាណសំវរៈ សកលមហាសង្ឃបរិនាយក ដែលជាសម្តេចព្រះសង្ឃរាជទី១៩ នៃព្រះរាជាណាចក្រថៃ, ជា “សម្តេចព្រះអគ្គសង្ឃរាជ”, ជា “ព្រះសង្ឃរបស់ប្រជាជន” ជាព្រះសង្ឃដែលទទួលបានការគោរពបូជាយ៉ាងក្រៃលែង និងជាជម្រកផ្លូវចិត្តនៃពុទ្ធបរិស័ទទូទៅជាច្រើនរហូត៕

ព្រះសង្ឃរាជមួយព្រះអង្គរបស់ប្រជាជន

សម្តេចព្រះញាណសំវរ ព្រះសង្ឃរាជនៃប្រទេសថៃ